FAMILY CARE FIRST | REACT



www.fcf-react.org

# កត្តារារាំង និងកត្តាជំរុញការថែទាំកុមារ មានពិការភាពដោយឪពុកម្តាយធម៌ នៅប្រទេសកម្ពុជា

Light for the World Cambodia, 2021

សហភាពអឺរ៉ុប | USAID | GHR FOUNDATION | Save the Children | unicef | LIGHT FOR THE WORLD

# អារម្ភកថា

ការស្រាវជ្រាវនៅទូទាំងពិភពលោកបានបង្ហាញថា កុមារដែលមានពិការភាពទំនងជាមិនសូវស្ថិតក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌នោះទេ បើទោះបីជាពួកគាត់ ត្រូវការប្រព័ន្ធថែទាំជំនួសជាខ្លាំង នៅពេលដែលពួកគាត់មិនអាចស្នាក់នៅជាមួយគ្រួសារបង្កើតរបស់ខ្លួនបានក៏ដោយ។ ស្ថានភាពនេះគឺដូចគ្នានៅក្នុងប្រទេសកម្ពុជា ក៏ដូចនៅប្រទេសផ្សេងទៀតដែរ។ ជម្រើសនៃការថែទាំជំនួសតាមគ្រួសារ សម្រាប់កុមារមានពិការភាព គឺមានតិចតួច ហើយប្រព័ន្ធមួយចំនួនដែលមាននោះ គឺផ្តោតតែនៅក្នុងតំបន់ភូមិសាស្ត្រតិចតួចប៉ុណ្ណោះ។

គោលការណ៍ណែនាំមួយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីផែនការសកម្មភាពដើម្បីកែលម្អការថែទាំកុមារ គឺផ្តោតទៅលើ “សមធម៌” ។ គោលការណ៍នោះបញ្ជាក់យ៉ាងច្បាស់ថា ចាំបាច់ត្រូវយកចិត្តទុកដាក់ពិសេសចំពោះកុមារដែលមាន “តម្រូវការពិសេស” ដើម្បីធានាថាពួកគាត់ "មិនត្រូវបានទុកចោលឡើយ" ។ ដូច្នេះមានតម្រូវការយ៉ាងខ្លាំងក្នុងការបញ្ជ្រាបសេវាថែទាំជំនួសតាមគ្រួសារ ដើម្បីកាត់បន្ថយការរើសអើងចំពោះកុមារមានពិការភាព ទាក់ទងនឹងសិទ្ធិមូលដ្ឋានរបស់ពួកគាត់ក្នុងការទទួលបានការយកចិត្តទុកដាក់ក្នុងគ្រួសារ និងសហគមន៍។

គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង ( Family Care First | REACT ) ( FCF) គឺជាបណ្តាញនៃអង្គការជាសមាជិកជាង ៦០ ដែលធ្វើការងាររួមគ្នា ដើម្បីគាំទ្រដល់កុមារឱ្យរស់នៅប្រកបដោយសុខសុវត្ថិភាព និងការចិញ្ចឹមបីបាច់នៅតាមគ្រួសារ។ ក្រុមការងារបច្ចេកទេសរបស់គម្រោង FCF អះអាងថា កុមារមួយក្រុម ជាពិសេសកុមារដែលមានពិការភាពទទួលរងនូវកង្វះខាតយ៉ាងធ្ងន់ធ្ងរនៃការទទួលស្គាល់ និងការបញ្ជូនទៅកាន់សេវាផ្សេងៗ។ ជាផ្នែកមួយនៃគម្រោង “មិនទុកកុមារណាម្នាក់ចោល” របស់បណ្តាញ FCF | REACT អង្គការឡៃហ្វ័រឌឺវើល ( Light for the World ) ប្រចាំនៅកម្ពុជា ផ្តោតទៅលើការលើកកម្ពស់បរិយាបន្នពិការភាព។ ដើម្បីរួមចំណែកពង្រឹងដល់ការងារនៅក្នុងវិស័យនេះ យើងបានធ្វើការសិក្សាមួយស្តីពីការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំកុមារដោយឪពុកម្តាយធម៌នៅក្នុងប្រទេសកម្ពុជា។ យើងមានសេចក្តីរីករាយ នឹងបង្ហាញពីលទ្ធផលនៃការសិក្សានោះនៅក្នុងរបាយការណ៍នេះ។

David Curtis
ទីប្រឹក្សាផ្នែកបរិយាបន្ន / អ្នកសម្របសម្រួលប្រចាំប្រទេស

Judith Baart
អ្នកស្រាវជ្រាវ
Light for the World Cambodia

LIGHT FOR THE WORLD

# សេចក្តីសង្ខេប

ដូចកុមារដទៃទៀតដែរ ហើយប្រហែលជាលើសពីកុមារដទៃទៀតផង ដោយសារភាពងាយរងគ្រោះរបស់ពួកគាត់ កុមារមានពិការភាពមានសិទ្ធិទទួលបានការថែទាំ និងការគាំទ្រយ៉ាងពេញលេញ ដើម្បីបំពេញតម្រូវការរបស់ខ្លួន។ ដោយអនុលោមតាមចំណុចនេះ យើងចង់ស្វែងយល់ថា តើអ្វីដែលរារាំងកុមារមានពិការភាពពីការដាក់បញ្ចូលទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌។ ដូច្នេះរបាយការណ៍នេះមានគោលបំណងឆ្លើយសំណួរថា "តើអ្វីជាកត្តារារាំង និងកត្តាជំរុញការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌នៅប្រទេសកម្ពុជា?"

ការសិក្សានេះរួមបញ្ចូលការសិក្សាលើអត្ថបទនានាដែលមានស្រាប់ ក៏ដូចជាកិច្ចសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ (ការសម្ភាសន៍ដោយប្រើបញ្ជីសំណួរ) ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ១០ នាក់ ដែលពួកគាត់ទាំងអស់គ្នាធ្វើការងារ ឬមានជំនាញនៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌នៅប្រទេសកម្ពុជា។

ការសិក្សានេះបង្ហាញឱ្យឃើញនូវកត្តារារាំងសំខាន់ៗចំនួន ៦ និងកត្តាជំរុញសំខាន់ៗចំនួន ៦ផងដែរ ចំពោះការថែទាំកុមារមានពិការភាពដោយឪពុកម្តាយធម៌។

កត្តារារាំងរួមមាន ៖

- ភាពភ័យខ្លាច និងការយល់ច្រឡំអំពីពិការភាព
- ការយល់ឃើញរបស់មណ្ឌលថែទាំកុមារមានពិការភាព
- អសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណកុមារមានពិការភាព និងតម្រូវការរបស់ពួកគេឱ្យបានច្បាស់លាស់
- កង្វះការត្រៀមលក្ខណៈ និងការគាំទ្រគ្រប់គ្រាន់ទៅដល់ឪពុកម្តាយធម៌
- កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់
- ភាពភ័យខ្លាចថា ការទុកដាក់ថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាពមានលក្ខណៈអចិន្ត្រៃយ៍

កត្តាជំរុញរួមមាន ៖

- លើកកម្ពស់ការយល់ដឹងអំពីពិការភាព ដើម្បីបង្កើនចំណេះដឹង និងលុបបំបាត់ជំនឿមិនពិត
- ការទទួលសេវាតាមប្រភេទពិការភាពជាក់លាក់នៅក្បែរផ្ទះឪពុកម្ដាយធម៌
- ការផ្ដល់ ការថែទាំ ដើម្បីមានពេលសម្រាកដល់គ្រួសារធម៌
- ការកំណត់អត្តសញ្ញាណយ៉ាងត្រឹមត្រូវ និងការធ្វើផែនការអចិន្ត្រៃយ៍
- ការរ៉ាប់រងថ្លៃចំណាយយ៉ាងគ្រប់គ្រាន់
- ចំណេះដឹង និងការយល់ដឹងអំពីជម្រើសផ្សេងៗនៃការថែទាំជំនួស

FAMILY CARE FIRST | REACT

# មាតិកា


អារម្ភកថា ........................................ 1
សេចក្តីសង្ខេប ........................................ 2
មាតិកា ........................................ 4
សេចក្តីផ្តើម ........................................ 5
វិធីសាស្រ្ត ........................................ 9
កត្តារាំងការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ ........................................ 11
ការភ័យខ្លាច និងការយល់ច្រឡំអំពីពិការភាព ........................................ 11
ការយល់ឃើញរបស់មណ្ឌលថែទាំកុមារមានពិការភាព ........................................ 12
អសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណកុមារមានពិការភាព និងតម្រូវការរបស់ពួកគេឱ្យបានច្បាស់លាស់ ........................................ 13
កង្វះការត្រៀមលក្ខណៈ និងការគាំទ្រគ្រប់គ្រាន់ទៅដល់ឪពុកម្តាយធម៌ ........................................ 15
កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់ ........................................ 16
ភាពភ័យខ្លាចថាការទុកដាក់ថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព មានលក្ខណៈអចិន្ត្រៃយ៍ ........................................ 18
កត្តាជំរុញការរួមបញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ ........................................ 21
លើកកម្ពស់ការយល់ដឹងអំពីពិការភាព ដើម្បីបង្កើនចំណេះដឹង និងលុបបំបាត់ជំនឿមិនពិត ........................................ 21
ការទទួលសេវាតាមប្រភេទពិការភាពជាក់លាក់ នៅក្បែរផ្ទះឪពុកម្តាយធម៌ ........................................ 21
ការផ្តល់ ការថែទាំ ដើម្បីមានពេលសម្រាកដល់គ្រួសារធម៌ ........................................ 24
ការកំណត់អត្តសញ្ញាណយ៉ាងត្រឹមត្រូវ និងការធ្វើផែនការអចិន្ត្រៃយ៍ ........................................ 24
ការរ៉ាប់រងថ្លៃចំណាយយ៉ាងគ្រប់គ្រាន់ ........................................ 26
ចំណេះដឹង និងការយល់ដឹងអំពីជម្រើសផ្សេងៗនៃការថែទាំជំនួស ........................................ 27
សេចក្តីសន្និដ្ឋាន ........................................ 29
អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម ........................................ 29
អ្នកផ្តល់ព័ត៌មានសំខាន់ៗ ........................................ 33
ឯកសារយោង ........................................ 34

# សេចក្តីផ្តើម

នៅពេលដែលកុមារមិនអាចរស់នៅក្នុងគ្រួសារបង្កើតរបស់ខ្លួន ដោយសារមូលហេតុអ្វីមួយ នោះចាំបាច់ត្រូវមានជម្រើសថែទាំជំនួសសម្រាប់ពួកគាត់។ នៅប្រទេសកម្ពុជា មូលហេតុចម្បងដែលមិនអាចបន្តរស់នៅក្នុងគ្រួសារបង្កើតរបស់ខ្លួនបាន គឺភាពក្រីក្រ ហើយជាញឹកញាប់តែងមានបញ្ហារួមផ្សំដទៃទៀត ដូចជា "ហិង្សា ការរំលោភបំពាន ជម្លោះគ្រួសារ ការបោះបង់ចោល ការធ្វើចំណាកស្រុក ការស្លាប់របស់ក្រុមគ្រួសារ ឬជំងឺ និងការញៀន" (Hamilton, Apland, Dunaiski, & Yarrow, 2017, p. 4) ។ មូលហេតុមួយទៀតនៃការទុកដាក់ក្នុងការថែទាំជំនួស ជាពិសេសចំពោះកុមារនៅតំបន់ជនបទ គឺគំនិតដែលថាការថែទាំជំនួសនឹងផ្តល់ឱ្យកុមារនូវការអប់រំប្រកបដោយគុណភាពខ្ពស់ដែលក្រុមគ្រួសារមិនអាចផ្តល់ឱ្យបាន ឬការថែទាំពិសេសដែលគ្រួសារមិនដឹងពីរបៀបផ្តល់ឱ្យ។ ប្រភេទនៃការថែទាំជំនួសដែលគេឃើញមាននៅក្នុងប្រទេសកម្ពុជារួមមាន៖ ការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ការថែទាំតាមវត្តអារាម ផ្ទះស្នាក់នៅជាក្រុម អន្តេវាសិកដ្ឋាន និងមណ្ឌលថែទាំកុមារ (Hamilton et al., 2017) ។ នៅក្នុងរបាយការណ៍នេះ យើងនឹងផ្តោតជាពិសេសទៅលើការថែទាំដោយឪពុកម្តាយធម៌។

ប្រភេទនៃការថែទាំជំនួស[1]

*ការថែទាំដោយសាច់ញាតិ៖* ជាការថែទាំតាមគ្រួសារនៅក្នុងសាខាញាតិរបស់កុមារ ឬជាមួយមិត្តភក្តិជិតស្និទ្ធរបស់គ្រួសារដែលកុមារស្គាល់ មិនចំពោះថាការថែទាំបែបនេះមានលក្ខណៈផ្លូវការ ឬមិនផ្លូវការឡើយ។

*ការថែទាំដោយឪពុកម្តាយធម៌៖* ជាស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទុកដាក់សម្រាប់គោលបំណងថែទាំជំនួស នៅក្នុងបរិយាកាសគ្រួសារក្នុងមូលដ្ឋានមួយដែលត្រូវបានជ្រើសរើស មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលការឯកភាព និងមានការត្រួតពិនិត្យតាមដានសម្រាប់ផ្តល់ការថែទាំបែបនេះ ។

*ការថែទាំតាមវត្តអារាម៖* ការថែទាំដែលផ្តល់ដល់កុមារដោយព្រះសង្ឃ ដូនជី និងអាចារ្យ ដែលជាញឹកញាប់ការថែទាំបែបនេះធ្វើឡើងនៅក្នុងវត្តអារាម។

*ផ្ទះស្នាក់នៅជាក្រុម៖* កុមារមួយចំនួនត្រូវបានទុកដាក់ឱ្យរស់នៅក្នុងបរិយាកាសគ្រួសារមួយក្រោមការត្រួតពិនិត្យពីអ្នកថែទាំមួយចំនួនតូចដែលមិនមែនជាសាច់ញាតិរបស់កុមារ។

*អន្តេវាសិកដ្ឋាន៖* ជាទូទៅពាក់ព័ន្ធនឹងការអប់រំ ប៉ុន្តែកុមារអាចនឹងត្រូវបានទុកដាក់នៅតាមអន្តេវាសិកដ្ឋាន ដោយសារបញ្ហាការពារកុមារនៅក្នុងគ្រួសារ។

*មណ្ឌលថែទាំកុមារ៖* មណ្ឌលដែលមិននៅតាមគ្រួសារ ហើយដំណើរការដោយបុគ្គលិកដែលទទួលប្រាក់កម្រៃ ជាទីដែលកុមាររស់នៅ និងប្រើប្រាស់សេវានានា ក៏ដូចជាគេងនៅពេលយប់ផងដែរ (ក្រសួងសង្គមកិច្ច ឆ្នាំ២០១៦)។

## ការថែទាំដោយឪពុកម្តាយធម៌

នៅក្នុងគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ ឆ្នាំ២០០៦ រដ្ឋាភិបាលកម្ពុជាឱ្យនិយមន័យ ការថែទាំដោយឪពុកម្តាយធម៌ថាជា “ទម្រង់នៃការទុកដាក់បណ្តោះអាសន្នមួយដែលគ្រួសារមួយយល់ព្រមទទួលយកកូនមិនជាប់សាច់ឈាមមកថែទាំ។ ជាធម្មតា វាមានរយៈពេលខ្លី ហើយមិនពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវរបស់ឪពុកម្តាយជាអចិន្ត្រៃយ៍នោះឡើយ (ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦)។ នៅប្រទេសកម្ពុជា ការថែទាំដោយឪពុកម្តាយធម៌ ភាគច្រើនត្រូវបាន

[1] (Hamilton et al., 2017)

ផ្តល់ឱ្យ និងគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល។ ដូច្នេះលក្ខណៈនៃការថែទាំដោយឪពុកម្តាយធម៌មានភាពខុសគ្នាទៅតាមអង្គការដែលគ្រប់គ្រងនោះ (Hamilton et al., 2017)។

ការថែទាំដោយគ្រួសារ ដូចជាការថែទាំដោយឪពុកម្តាយធម៌ ត្រូវបានគេចាត់ទុកថាជាជម្រើសដែលប្រសើរជាងការថែទាំនៅមណ្ឌល។ គេក៏ដឹងនៅទូទាំងពិភពលោកផងដែរថា ជាញឹកញាប់កុមារមានពិការភាព ត្រូវបានបដិសេធពីការថែទាំដោយឪពុកម្តាយធម៌ (EveryChild, 2011) ។ គោលនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជា ស្តីពីការថែទាំជំនួសសម្រាប់កុមារ ក៏ទទួលស្គាល់ផងដែរថា "វាមិនមែនជារឿងចម្លែកទេ ដែលយើងឃើញកុមារមានពិការភាពនៅក្នុងមណ្ឌលថែទាំកុមារ គឺមួយផ្នែកដោយសារពួកគេទំនងជាត្រូវបានបោះបង់ចោលច្រើនជាងកុមារដទៃ ហើយមិនសូវត្រូវបានទុកដាក់ថែទាំតាមគ្រួសារ និងសហគមន៍ទេ" (ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ទំព័រ២៣) ។

## កុមារមានពិការភាពក្នុងការថែទាំជំនួសនៅកម្ពុជា

មានព័ត៌មានតិចតួចអំពីវិសាលភាពដែលកុមារមានពិការភាព ត្រូវបានទុកដាក់ក្នុងការថែទាំជំនួស ជាពិសេសការថែទាំដោយឪពុកម្តាយធម៌។ ការធ្វើផែនទីសិក្សាមួយនៅ ឆ្នាំ២០១៦ បានរកឃើញថា មានកុមារមានពិការភាពចំនួន ៩២៥ នាក់ រស់នៅក្នុងមណ្ឌលថែទាំ ក្នុងចំណោមកុមារសរុបចំនួន ១៦.៥៧៩ នាក់ (ក្រសួងសង្គមកិច្ច ឆ្នាំ២០១៦)។ មានព័ត៌មានតិចតួចណាស់អំពីចំនួននៃកុមារមានពិការភាពដែលរស់នៅក្នុងទម្រង់ផ្សេងៗទៀតនៃការថែទាំជំនួស។

## សំណួរស្រាវជ្រាវ

ដូចកុមារដទៃទៀតដែរ ហើយប្រហែលជាលើសពីកុមារដទៃទៀតផង ដោយសារភាពងាយរងគ្រោះរបស់ពួកគេ កុមារមានពិការភាព មានសិទ្ធិទទួលបានការថែទាំ និងការគាំទ្រយ៉ាងពេញលេញ ដើម្បីបំពេញតម្រូវការរបស់ខ្លួន។ ហេតុដូចនេះ យើងចង់ស្វែងយល់ថា តើអ្វីដែលរារាំងកុមារមានពិការភាពពីការដាក់បញ្ចូលទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌។ ដូច្នេះរបាយការណ៍នេះ មានគោលបំណងឆ្លើយសំណួរ ៖ "តើអ្វីជាកត្តារារាំង និងកត្តាជំរុញការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌នៅប្រទេសកម្ពុជា?"



# វិធីសាស្ត្រ

ជំហានដំបូង ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយពិនិត្យលើឯកសារមានស្រាប់។ ដៃគូពាក់ព័ន្ធសំខាន់ៗបានចែករំលែកឯកសារ និងគោលនយោបាយសំខាន់ៗ ហើយយើងក៏បានធ្វើការស្រាវជ្រាវតាមអ៊ីនធឺណិតដោយប្រើពាក្យគន្លឹះបីគឺ"ការថែទាំដោយឪពុកម្តាយធម៌" "កុមារមានពិការភាព" និង “កម្ពុជា” ។ គេហទំព័រ បណ្តាញថែទាំល្អប្រសើរ ( Better Care Network ) ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវលើអត្ថបទ ដោយឯកសារទាំងអស់ត្រូវបានពិនិត្យរកពាក្យគន្លឹះទាំងបីនេះ។

ជំហានទីពីរ “កិច្ចសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ( ការសម្ភាសន៍ដោយប្រើបញ្ជីសំណួរ )” ត្រូវបានធ្វើឡើងជាមួយអ្នកផ្តល់ព័ត៌មាន ចំនួន ១០ នាក់។ ហើយអ្នកផ្តល់ព័ត៌មានទាំងអស់នោះ គឺជាអ្នកបានធ្វើការ ឬកំពុងធ្វើការនៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ នៅជួររដ្ឋាភិបាល និងឬ អង្គការធ្វើការផ្នែកពិការភាពជាក់លាក់ និងមានបទពិសោធជំនាញផ្ទាល់ក្នុងការថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាពនៅកម្ពុជា។ បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ មាននៅទំព័រ ៣៣។ បទសម្ភាសន៍ត្រូវបានធ្វើឡើង និងវិភាគដោយអ្នកស្រាវជ្រាវ។ លើសពីនេះទៀត បុគ្គលិកអង្គការ Light for the World បានជួបជាមួយសមាជិកនៃនាយកដ្ឋានសុខុមាលភាពកុមារ និងនាយកដ្ឋានសុខុមាលភាពជនពិការ ដើម្បីពិភាក្សាអំពីប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ ព្រមទាំងបានទទួលយោបល់ត្រឡប់អំពីលទ្ធផលស្រាវជ្រាវ។ លទ្ធផលក៏ត្រូវបានពិភាក្សាជាមួយបុគ្គលិកជំនាញមកពីអង្គការ Light for the World ផងដែរ[2] ។

របាយការណ៍នេះត្រូវបានបែងចែកជាពីរផ្នែកធំៗ ផ្នែកទី១ និយាយអំពីកត្តារារាំងការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ ផ្នែកទី២ និយាយអំពីកត្តាជំរុញការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌។

---

[2] Including Virak Kheng, David Curtis and Marieke Boersma.



# កត្តារារាំងការដាក់បញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌

## ការភ័យខ្លាច និងការយល់ច្រឡំអំពីពិការភាព

ទោះបីជាមិនមានរៀបរាប់នៅក្នុងអត្ថបទស្រាវជ្រាវក៏ដោយ តែអ្នកឆ្លើយស្ទើរតែទាំងអស់គ្នាបានលើកឡើងថា ជំនឿ និងការមាក់ងាយជុំវិញពិការភាព គឺជាកត្តារារាំងមួយនៃការថែទាំកុមារមានពិការភាពដោយឪពុកម្តាយធម៌។ ឧទាហរណ៍ ពិការភាពអាចត្រូវគេមើលឃើញថា ជាការនាំមកនូវសំណាងអាក្រក់ និងជាសញ្ញានៃកម្មពៀរមិនល្អ ហើយការនាំជនមានពិការភាពចូលក្នុងផ្ទះ អាចជាការនាំសំណាងអាក្រក់ចូលមកក្នុងផ្ទះ។

> "អ្នកខ្លះនៅតែនិយាយថា [ពិការភាព] នាំមកនូវសំណាងអាក្រក់ដល់គ្រួសារ។ ពួកគេបានសាងបាបកាលពីជាតិមុន ទើបជាតិនេះត្រូវពិការបែបនេះ" ។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

> “ឪពុកម្តាយមិនយល់ថា កុមារមិនមែនចង់កើតមកជាមួយភាពពិការភាពនោះទេ។ [...] យើងឃើញថា មិនមានគ្រួសារច្រើនប៉ុន្មានទេដែលមានឆន្ទៈផ្តល់ការថែទាំជនមានពិការភាព” ។ (អ្នកចូលរួមទី៦ ឆ្នាំ២០២០)

ការស្រាវជ្រាវពីមុនដោយអង្គការ Light for the World ក្នុងចំណោមប្រធានគ្រប់គ្រងនៃអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារជាមួយកុមារ បានបង្ហាញថា ភាគច្រើនពួកគាត់យល់ថា ក្រុមគ្រួសាររបស់កុមារមានពិការភាពត្រូវបានគេរើសអើងនៅក្នុងសហគមន៍។ ឧទាហរណ៍ ការរើសអើងមានដូចជា៖ ការមិនអនុញ្ញាតឱ្យកុមារដទៃទៀតលេងជាមួយកុមារមានពិការភាព ដោយជំនឿថាជនមានពិការភាពមិនមានអនាម័យល្អ ឬជំជឿថាគ្រួសារគាត់បានសាងបាប ទើបមានកូនពិការ (Light for the World Cambodia នាពេលខាងមុខ) ។

បន្ថែមពីលើការមាក់ងាយទៀត មនុស្សជាច្រើនក្នុងប្រទេសកម្ពុជា គឺមិនសូវយល់ពីពិការភាពតែម្តង ឬមិនយល់ពីគំនិតដែលថា ពិការភាពអាចប្រែប្រួល ឬបានប្រសើរឡើងតាមពេលវេលា។ ពួកគាត់ប្រហែលជាមិនដឹងថា ពិការភាពរបស់មនុស្សម្នាក់ មានលទ្ធផលបែបណាទេពាក់ព័ន្ធនឹងការអភិវឌ្ឍ ការថែទាំ និងការរំពឹងទុកនាពេលអនាគត។ ការមិនយល់ពីពិការភាព (របស់កុមារណាម្នាក់) អាចធ្វើឱ្យពួកគេភ័យខ្លាចថានឹងធ្វើខុសឆ្គងក្នុងការថែទាំ ឬស្ទាក់ស្ទើរក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារនោះ។

ដោយសារតែគំនិតជុំវិញពិការភាពទាំងនេះហើយ ទើបមានទស្សនៈវិស័យតិចតួចណាស់ដែលថា កុមារមានពិការភាពត្រូវបានធ្វើសមាហរណកម្មទៅក្នុងគ្រួសារបង្កើតរបស់ខ្លួនវិញ។ អង្គការប្រព័ន្ធថែទាំដោយឳពុកម្តាយធម៌មួយចំនួនបានរាយការណ៍ថា ធ្លាប់បានជួបឳពុកម្តាយជាច្រើនលើកច្រើនសារ ហើយពេលខ្លះថែមទាំងទុកកុមារចោលមួយរយៈពេលខ្លី ដើម្បីផ្តល់ពេលវេលាឱ្យគ្រួសារទម្លាប់នឹងកូនរបស់ពួកគាត់វិញ។ ជារឿយៗ ទោះបីជាធ្វើបែបនេះក៏ដោយ ក្រុមគ្រួសារនៅតែមិនចង់យកកូនរបស់ខ្លួនត្រឡប់មកវិញដដែល។ នេះអាចមានន័យថា ការថែទាំដោយឳពុកម្តាយធម៌ បើទោះជាក្នុងបំណងជាដំណោះស្រាយបណ្តោះអាសន្នក៏ដោយ ក៏ចុងក្រោយវានៅតែមានភាព អចិន្ត្រៃយ៍សម្រាប់កុមារមានពិការភាព ក្នុងកម្រិតខ្ពស់ជាងកុមារដែលគ្មានពិការភាព។

> “វាមានការលំបាកក្នុងការធ្វើសមាហរណកម្មកុមារមានពិការភាព [ទៅក្នុងគ្រួសារបង្កើតរបស់គាត់វិញ]។ [...] ពីព្រោះនៅពេលដែលយើងទៅជួប [គ្រួសារ] ពួកគាត់គិតថាយើងនាំបញ្ហាទៅឱ្យគ្រួសារគាត់។ ពួកគាត់គិតថាកុមារមានពិការភាព គឺមិនងាយស្រួលថែទាំទេ នាំមកនូវបញ្ហាផ្សេងៗ” ។ (អ្នកចូលរួមទី៨ ឆ្នាំ២០២០)

ចំណុចនេះ គឺដូចគ្នាដែរសម្រាប់ឳពុកម្តាយធម៌។ វាជាការលំបាកក្នុងការស្វែងរកឳពុកម្តាយធម៌សម្រាប់កុមារមានពិការភាព ព្រោះ “ឳពុកម្តាយជាច្រើនបដិសេធកូនធម៌ដែលមានពិការភាព។ ពួកគាត់គិតថា គាត់ពិបាកខ្លាំងណាស់ក្នុងការថែទាំកុមារ” ។ (អ្នកចូលរួមទី៨ឆ្នាំ២០២០)

> “វាលំបាកណាស់ក្នុងការស្វែងរកឳពុកម្តាយធម៌រយៈពេលខ្លីសម្រាប់ [កុមារមានពិការភាព] ។ ពួកគាត់មានអារម្មណ៍ថាគាត់គ្មានជំនាញទេ។ ពួកគាត់ភ័យខ្លាចដោយសារតែមិនយល់ពីពិការភាព”។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “ភាគច្រើនឳពុកម្តាយធម៌បណ្តោះអាសន្ន យល់ថាគាត់មិនមានលទ្ធភាព និងជំនាញក្នុងការថែទាំកុមារដែលមានពិការភាពធ្ងន់ធ្ងរនោះឡើយ។ សំខាន់ជាងនេះទៅទៀត គឺពួកគាត់ភ័យខ្លាចថាថែទាំកុមារនោះមិនបានល្អ"។ (អ្នកចូលរួមទី១ ឆ្នាំ២០២០)

## ការយល់ឃើញរបស់មណ្ឌលថែទាំកុមារមានពិការភាព

នៅតែមានការប្រើប្រាស់មណ្ឌលថែទាំយ៉ាងច្រើនសម្រាប់កុមារមានពិការភាព (EveryChild, 2011) ។ ជាទូទៅ សូម្បីតែចំពោះកុមារដែលគ្មានពិការភាពក៏ដោយ ជម្រើសថែទាំនៅមណ្ឌល គឺត្រូវបានចាត់ទុកថាជាដំណោះស្រាយដ៏ប្រសើរបំផុត សម្រាប់កុមារដែលត្រូវការការថែទាំជំនួស ដោយភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិនៅកម្ពុជា ដែលត្រូវបានសម្ភាស បានលើកឡើងយ៉ាង

ដូច្នេះ (UNICEF 2011) ។ លើសពីនេះទៀត សម្រាប់កុមារដែលមានពិការភាព វាជាករណីកាន់តែញឹកញាប់ទៅទៀត ដែលមណ្ឌលថែទាំ ត្រូវបានគេចាត់ទុកថាជាកន្លែងថែទាំជំនួស ដែលពេញនិយមច្រើន។ នេះដោយសារតែមណ្ឌលថែទាំកុមារ ត្រូវបានគេមើលឃើញថាមានអ្នកជំនាញ និងការគាំទ្រប្រកបដោយវិជ្ជាជីវៈ ដើម្បីផ្តល់ការថែទាំចាំបាច់ដល់កុមារមានពិការភាព ហើយដែលឪពុកម្តាយធម៌មិនអាចផ្តល់បាន។

> “មណ្ឌលថែទាំកុមារ ជាជម្រើសដែលគេត្រូវការ ពីព្រោះ] វាជាកន្លែងដែលមានទីធ្លា ហើយមានអ្នកជំនាញ ដើម្បីគាំទ្រដល់ពួកគាត់” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “មិនមែនគ្រប់កុមារមានពិការភាពទាំងអស់ គួរតែស្ថិតក្នុងការថែទាំដោយឪពុកម្តាយធម៌នោះទេ។ មានករណីខ្លះ ដែលប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ មានភាពសមស្របយ៉ាងខ្លាំង។ ចំពោះកុមារផ្សេងទៀត គេប្រហែលជាមានចំណាប់អារម្មណ៍លើមណ្ឌលថែទាំទៅវិញ។ [...] កុមារម្នាក់ដែលមាន ពិការភាពធ្ងន់ធ្ងរ និងមានពិការភាពច្រើនប្រភេទ ត្រូវការបុគ្គលិកជំនាញ។ ក្រុមគ្រួសារមិនអាចធ្វើដូច្នេះបានទេ។ [...] បរិយាកាសគ្រួសារ គឺល្អបំផុត ប៉ុន្តែពួកគាត់ត្រូវការលើសពីនេះ។ ពួកគាត់ត្រូវការអ្នកឯកទេស អ្នកជំនាញ ដើម្បីផ្តល់ការថែទាំយ៉ាងល្អដល់ពួកគេបាន” ។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

> “ប្រសិនបើកុមារម្នាក់មានពិការភាព ឬមានការពិបាកផ្នែកផ្លូវចិត្ត នោះពួកគាត់[គ្រួសារ] គិតថាល្អបំផុតគួរតែ ទុកចោលនៅមន្ទីរពេទ្យ ឬបោះបង់ចោលឱ្យអង្គការ ឬទុកនៅក្នុងមណ្ឌលថែទាំ ដែលភាគច្រើនគេតែងតែធ្វើបែបនេះ។ ពួកគាត់ដឹងថាប្រទេសកម្ពុជាមានកន្លែងសម្រាប់កុមារទាំងនោះរស់នៅឯមណ្ឌលថែទាំ។ ពួកគាត់គិតថាការរស់នៅទីនោះ គឺប្រសើរសម្រាប់កុមារ ជាជាងការថែទាំដោយខ្លួនឯង” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

## អសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណកុមារមានពិការភាព និងតម្រូវការរបស់ពួកគេឱ្យបានច្បាស់លាស់

ដើម្បីមានលទ្ធភាពជួយដល់កុមារមានពិការភាព និងគ្រួសារធម៌របស់គាត់ ជាដំបូងគឺត្រូវកំណត់អត្តសញ្ញាណកុមារមានពិការភាពទាំងនេះឱ្យច្បាស់លាស់ជាមុនសិន។ ប្រសិនបើបុគ្គលិកគ្រប់គ្រងករណី ដែលទទួលខុសត្រូវក្នុងការទុកដាក់កុមារទៅក្នុងគ្រួសារធម៌ និងគាំទ្រកុមារក្នុងដំណើរការទុកដាក់ថែទាំជាមួយគ្រួសារធម៌ មិនអាចកំណត់អត្តសញ្ញាណ និងវាយតម្លៃកុមារមានពិការភាពឱ្យបានត្រឹមត្រូវ នោះអាចបណ្តាលឱ្យមាន “របាយការណ៍មិនគ្រប់គ្រាន់ ការសម្រេចចិត្តទុកដាក់ថែទាំ

មិនសមរម្យ និងការផ្តល់សេវាមិនបានគ្រប់គ្រាន់ដល់កុមារ និងយុវជនដែលមានពិការភាពក្នុងពេលថែទាំដោយឪពុកម្តាយធម៌” (United Cerebral Palsy & Children's Rights, 2006, p. 6) ។

អ្នកផ្តល់ព័ត៌មានសំខាន់ៗបានបង្ហាញថា បុគ្គលិកសង្គមមិនមានការយល់ដឹងច្រើនអំពីពិការភាពទេ។ បុគ្គលិកសហគមន៍នៅកម្ពុជា ក៏មិនបានបណ្តុះបណ្តាលឱ្យបានច្បាស់លាស់អំពីរបៀបកំណត់អត្តសញ្ញាណកុមារមានពិការភាពផងដែរ (Jenny, Martin, & Burn, n.d.) ជាការខ្វះខាតជំនាញមួយដែលទទួលស្គាល់ដោយនាយកដ្ឋានសុខុមាលភាពកុមារ (លោក ខេង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២០) ។ អង្គការមួយដែលផ្តល់ប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ បានបញ្ជាក់ថា “យើងត្រូវធ្វើការងារជាមួយដៃគូ ដើម្បីកំណត់អត្តសញ្ញាណពិការភាព។ ពិការភាពខ្លះពិបាកនឹងមើលឃើញ។ វាពិតជាលំបាកណាស់ក្នុងការបណ្តុះបណ្តាលបុគ្គលិកសង្គម អំពីរបៀបកំណត់អត្តសញ្ញាណ” ។ (អ្នកចូលរួមទី៦ ឆ្នាំ២០២០)

ជាទូទៅ បុគ្គលិកសង្គមប្រហែលជាមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការ ហើយនិងមានវិញ្ញាបនបត្រក្នុងវិស័យការងារសង្គមនេះទេ ប៉ុន្តែមានការរៀនសូត្រពីការងារផ្ទាល់ ដូចបានបង្ហាញក្នុងការសិក្សាមួយថា មានបុគ្គលិកជួរមុខតែ ៣៩.២% ប៉ុណ្ណោះដែលមានសញ្ញាបត្រផ្នែកចិត្តវិទ្យា ឬផ្នែកការងារសង្គម (Roby, 2020) ។ ការបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈសម្រាប់បុគ្គលិកសង្គម គឺទើបតែមាននៅពេលថ្មីៗនេះទេ ដោយនិស្សិតវគ្គទី១ កម្រិតបរិញ្ញាបត្រការងារសង្គម បានចាប់ផ្តើមការសិក្សារយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ២០០៨ ហើយកម្មវិធីកម្រិតអនុបណ្ឌិតដំបូងបង្អស់ផ្នែកការងារសង្គម បានចាប់ផ្តើមនៅឆ្នាំ២០០៩ (រេតជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ។ ទោះជាយ៉ាងនេះក្តី មិនមានសិស្សគ្រប់គ្រាន់បានចូលរៀនក្នុងកម្មវិធីផ្នែកការងារសង្គម ដើម្បីឆ្លើយតបតាមតម្រូវការនោះទេ (អ្នកចូលរួមទី៣ ឆ្នាំ២០២០) ។ ជាញឹកញាប់ បុគ្គលិកសង្គមមិនទទួលបានប្រាក់កម្រៃច្រើននោះទេ ឬសូម្បីតែការបណ្តុះបណ្តាលជាក់លាក់អំពីពិការភាពក៏មិនទទួលបានដែរ ហើយពួកគាត់ពឹងផ្អែកលើដៃគូដែលធ្វើការលើពិការភាពចំពោះការគាំទ្រដល់ពួកគាត់ទៅតាមភាពចាំបាច់ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)។ ប៉ុន្តែដោយសារបុគ្គលិកសង្គម គឺជាមនុស្សដំបូងដែលក្រុមគ្រួសារ និងកុមារអាចទាក់ទង នេះអាចមានន័យថា ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃអាចនឹងយឺតពេលទៅហើយ ឬមិនបានធ្វើតែម្តង។ អង្គការក្រៅរដ្ឋាភិបាលខ្លះបញ្ជាក់ថា បុគ្គលិកសង្គមរបស់ពួកគាត់ដែលមានស្រាប់ បានទទួលការបណ្តុះបណ្តាលអំពីការវាយតម្លៃ និងការកំណត់អត្តសញ្ញាណពិការភាព ប៉ុន្តែបុគ្គលិកសង្គមដែលទើបតែមកថ្មី គឺមិនទាន់ទទួលបាននោះទេ (អ្នកចូលរួមទី៣ ឆ្នាំ២០២០) ដែលចំណុចនេះបង្ហាញថា ការបណ្តុះបណ្តាលអំពីពិការភាព គឺជាព្រឹត្តិការណ៍ដែលមិនមានការគ្រោងទុក សម្រាប់បុគ្គលិកគ្រប់គ្រងករណីទុកដាក់កុមារ ដើម្បីទទួលការថែទាំ។

# កង្វះការត្រៀមលក្ខណៈ និងការគាំទ្រគ្រប់គ្រាន់ទៅដល់ឪពុកម្ដាយធម៌

ទោះបីជាគ្រួសារឪពុកម្ដាយធម៌មានបំណង និងមានឆន្ទៈទទួលថែទាំកុមារមានពិការភាពក៏ដោយ ក៏ពួកគាត់មានការភ័យខ្លាច ថាមិនអាចផ្ដល់ការថែទាំគ្រប់គ្រាន់ដល់កុមារនោះដែរ។ ឪពុកម្ដាយធម៌អាចមានអារម្មណ៍ភ័យខ្លាចចំពោះពិការភាព និងតម្រូវការថែទាំខ្ពស់របស់កុមារ រួមទាំងមានការទទួលខុសត្រូវខ្ពស់។ ក្នុងករណីដែលកុមារមិនមានពិការភាពធ្ងន់ធ្ងរ ពួកគាត់អាចបារម្ភពីតម្រូវការថែទាំខ្ពស់ បើទោះជាវាមិនមែនជាការពិតសម្រាប់កុមារម្នាក់នោះក៏ដោយ។

> “ចំណុចសំខាន់គឺថា តើគ្រួសារបានត្រៀមលក្ខណៈរួចរាល់ឬទេ មុននឹងទទួលយកកុមារ។ វានឹងមានស្ថានភាពដែលមិនបានរំពឹងទុក ប៉ុន្តែការត្រៀមលក្ខណៈបានល្អប្រសើរ នោះឱកាសជោគជ័យមានកាន់តែខ្ពស់"។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

កង្វះការត្រៀមលក្ខណៈប្រឈមនឹងបញ្ហាដែលទាក់ទងនឹងការថែទាំកុមារមានពិការភាព គឺជាបញ្ហាជាសាកលក្នុងចំណោមឪពុកម្ដាយធម៌។ ដោយសារកម្មវិធីជ្រើសរើសឪពុកម្ដាយធម៌ ជាទូទៅមិនផ្ដោតទៅលើពិការភាពទេ នោះឪពុកម្ដាយធម៌ប្រហែលជាមិនបានទទួលព័ត៌មានមូលដ្ឋានអំពីតម្រូវការរបស់កុមារដែលត្រូវបានទុកដាក់ថែទាំនៅក្នុងគ្រួសាររបស់គាត់ ឬបានទទួលការបណ្ដុះបណ្ដាលពីរបៀបថែទាំតាមតម្រូវការជាក់លាក់របស់កូនធម៌នោះទេ (United Cerebral Palsy & Children's Rights, 2006)។ ជាញឹកញាប់ ការមិនបានត្រៀមលក្ខណៈផ្លូវចិត្តសម្រាប់ការទទួលថែទាំកុមារមានពិការភាព ត្រូវបានលើកឡើងជាមូលហេតុមួយដែលគេមិនចង់ថែទាំកុមារមានពិការភាព (Save the Children & Center for Educational Research and Consulting, 2013) ។

នៅពេលដែលឪពុកម្ដាយធម៌ មិនបានត្រៀមលក្ខណៈគ្រប់គ្រាន់មុននឹងទទួលថែទាំកុមារ ឬមិនត្រូវបានគាំទ្ររហូតចប់ការទុកដាក់ថែទាំទេ នោះវាអាចបណ្ដាលឱ្យមានស្ថានភាពគ្រោះថ្នាក់កើតឡើង។ ដូចដែលបានកត់សម្គាល់ដោយ Jenny et al. “[យើងសង្កេតឃើញថា] ឪពុកម្ដាយធម៌ទទួលការបណ្ដុះបណ្ដាល និងការគាំទ្រតិចតួចក្នុងការថែទាំតាមតម្រូវការរបស់កុមារ។ យើងមានអារម្មណ៍ថា ការទុកដាក់ថែទាំបែបនោះ គឺមិនសមស្របទេ ហើយអាចនឹងធ្វើឱ្យកុមារប្រឈមគ្រោះថ្នាក់ទៀតផង” (Jenny et al., n.d.) ។ អ្នកផ្ដល់ព័ត៌មានដទៃទៀត ក៏មានការសង្កេតស្រដៀងគ្នានេះដែរ ៖

> “[ឪពុកម្ដាយធម៌] ភ័យខ្លាចចំពោះពិការភាព។ ពួកគាត់ត្រូវការការថែទាំ ២៤ម៉ោង។ ប្រសិនបើផ្ដល់អាហារមិនត្រឹមត្រូវទេ [កុមារ] អាចស្លាប់ក្នុងពេលពីរនាទីប៉ុណ្ណោះ"។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “[កូនធម៌] មានពិការភាពធ្ងន់ធ្ងរ។ គ្មាននរណាបានប្រាប់ឪពុកម្តាយធម៌ពីរឿងនេះទេ។ ពួកគាត់មិនបានត្រៀមខ្លួនសោះ។ [...] ឪពុកម្តាយធម៌ថ្មី មានការភ័យខ្លាចជាខ្លាំង។ [ពួកគាត់] មិនបានទទួលការបណ្តុះបណ្តាលអំពីរបៀបផ្តល់អាហារ របៀបផ្តល់ថ្នាំឱ្យកុមារនោះទេ” ។ (អ្នកចូលរួមទី៤ ឆ្នាំ២០២០)

ឪពុកម្តាយធម៌ត្រូវការព័ត៌មានគ្រប់គ្រាន់អំពីពិការភាពជាទូទៅ និងអំពីពិការភាពរបស់កុមារ(បើមាន) ជាពិសេស គឺដើម្បីធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ ថាតើអាចទទួលយកកុមារម្នាក់នោះដែរឬទេ ហើយក៏ដើម្បីត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការថែទាំផងដែរ។ បច្ចុប្បន្នចំណុចនេះហាក់ដូចជាមិនត្រូវបានអនុវត្ត និងលើកមកពិភាក្សានៅក្នុងកម្មវិធីជ្រើសរើសឪពុកម្តាយធម៌នោះទេ ។ សូម្បីតែការសម្រេចចិត្តថា តើគួរថែទាំកុមារមានពិការភាពឬអត់ ក៏ត្រូវការការពិចារណាឱ្យហ្មត់ចត់ដែរ។ ដូចដែលបានរៀបរាប់ដោយអ្នកផ្តល់ព័ត៌មានម្នាក់ថា “ពិការភាពមានច្រើនប្រភេទ៖ តើអ្នកធ្វើដូចម្តេចនៅក្នុងដំណើរការជ្រើសរើសឪពុកម្តាយ? ប្រសិនបើអ្នកសួរឪពុកម្តាយ ថាតើគាត់ចង់បានកូនមានពិការភាពឬទេ នោះអ្នកត្រូវរៀបរាប់ចំណុចជាច្រើន។ វាអាចមានន័យថា កុមារមានពិការភាពកម្រិតស្រាល ឬមានពិការភាពយ៉ាងធ្ងន់ធ្ងរ” ។ (អ្នកចូលរួមទី១ ឆ្នាំ២០២០)

## កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់

> “សមត្ថភាពរបស់យើងនៅមានកម្រិតក្នុងការធ្វើការងារជាមួយកុមារមានពិការភាព។ ដូច្នេះ យើងពិបាកនឹងធ្វើការជាមួយកុមារមានពិការភាពណាស់។ យើងព្យាយាមស្វែងរកសេវាសម្រាប់គាំទ្រដល់ពួកគាត់ ព្រមទាំងបុគ្គលិកសង្គមរបស់យើង។ យើងមិនមានសេវាដែលឆ្លើយតបនឹងតម្រូវការនោះទេ។ យើងលំបាកក្នុងការវាយតម្លៃពួកគាត់ ហើយពិបាកធ្វើការងារជាមួយគាត់” ។ (អ្នកចូលរួមទី៨ ឆ្នាំ២០២០)

មូលហេតុចម្បងមួយដែលកុមារមានពិការភាពនៅកម្ពុជា ត្រូវបានគេទុកដាក់ថែទាំក្នុងមណ្ឌល ជាជាងនៅក្នុងគ្រួសារបង្កើត ឬគ្រួសារធម៌នោះព្រោះថា ជាញឹកញាប់គេឃើញមានកង្វះខាតសេវាតាមប្រភេទពិការភាពជាក់លាក់នៅក្នុងសហគមន៍ភាគច្រើន។ មណ្ឌលថែទាំកុមារត្រូវបានចាត់ទុកជាកន្លែងផ្តល់ការថែទាំ និងសេវាដែលកុមារមានពិការភាពត្រូវការ (នេះមិនទាន់ពិភាក្សាថា តើសេវាកម្មដែលពួកគេផ្តល់ឱ្យនោះ មានគុណភាពគ្រប់គ្រាន់ដែរឬទេ) (អង្គការយូនីសេហ្វ ឆ្នាំ២០១១) ។ ការសិក្សាមួយស្តីពីការថែទាំជំនួសនៅកម្ពុជា រកឃើញថា នៅក្នុងតំបន់ដែលមានបណ្តាញរឹងមាំក្នុងចំណោមអ្នកផ្តល់សេវា - ផ្តល់កម្មវិធីស្តីពីអន្តរាគមន៍ទាន់ពេលវេលា ការបង្ការ និងការស្តារនីតិសម្បទា

ក្នុងសហគមន៍ -ទីនោះមិនសូវមានកុមារមានពិការភាពស្នាក់នៅក្នុងមណ្ឌលថែទាំនោះទេ (Jenny et al., n.d.) ។

"ដរាបណាប្រជាជនមើលឃើញថា មានសេវាដែលអាចរកបានសម្រាប់ពួកគាត់នៅក្នុងសហគមន៍ នោះយើងអាចបង្ការការបែកចេញពីគ្រួសារតាំងពីដំបូងទី។ ខ្ញុំគិតថា ឪពុកម្ដាយដែលបោះបង់កូនមានពិការភាពចោលបន្ទាប់ពីសម្រាល នោះដោយសារពួកគាត់មិនដឹងថាត្រូវធ្វើដូចម្ដេចជាមួយកូន។ គាត់មិនដឹងពីរបៀបផ្ដល់ការថែទាំដល់កុមារ។ សេវានៅក្នុងសហគមន៍មិនមាន ឬមានតិចតួចណាស់ សម្រាប់ឱ្យពួកគាត់ស្វែងរកការគាំទ្រដល់កុមារមានពិការភាព។ បើគ្មានសេវាកម្ម និងចំណេះដឹងអំពីការថែទាំកុមារ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគាត់ទេ (ពួកគាត់ក្រីក្រ) ខ្ញុំគិតថាគាត់នឹងបោះបង់កូនមានពិការភាពនោះចោល។ ប៉ុន្តែប្រសិនបើពួកគាត់ដឹងថាមានសេវាកម្ម មានអ្នកជួយគាំទ្រកុមារឱ្យការអភិវឌ្ឍទៅតាមសមត្ថភាព នោះខ្ញុំគិតថាពួកគាត់នឹងមិនបោះបង់ចោលកូនរបស់គាត់ទេ" ។ (អ្នកចូលរួមទី៩ ឆ្នាំ ២០២០)

"ខ្ញុំស្រមៃថាក្នុងរយៈពេល ១០ឆ្នាំខាងមុខ កុមារដែលមានពិការភាពច្រើនប្រភេទ និងធ្ងន់ធ្ងរនៅប្រទេសកម្ពុជា ត្រូវការជំនួយពីបុគ្គលិកឯកទេស។ ក្រុមគ្រួសារមិនអាចធ្វើដូច្នេះបានទេ។ ពួកគាត់មិនត្រូវបានបណ្ដុះបណ្ដាលកិច្ចការដូច្នេះទេ។ បរិយាកាសគ្រួសារ គឺល្អបំផុត ប៉ុន្តែពួកគាត់មានតម្រូវការលើសពីនេះ។ ពួកគាត់ត្រូវការអ្នកឯកទេស ពួកគាត់ត្រូវការអ្នកជំនាញដើម្បីថែទាំកូនគាត់ឱ្យបានល្អ" ។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

ទាំងឪពុកម្ដាយបង្កើត និងឪពុកម្ដាយធម៌ ត្រូវការសេវាសហគមន៍សម្រាប់កុមារមានពិការភាព ដើម្បីឱ្យពួកគាត់អាចចិញ្ចឹមកូននៅក្នុងសហគមន៍ ជាជាងបញ្ជូនទៅមណ្ឌលថែទាំ។ សេវាទាំងនេះអាចរួមបញ្ចូលសេវាវេជ្ជសាស្ត្រ សេវាស្ដារនីតិសម្បទា ការព្យាបាល ការថែទាំដើម្បីមានពេលសម្រាក ឬមណ្ឌលថែទាំពេលថ្ងៃ។

"យើងរកឃើញថា នៅពេលដែលគ្រួសារដឹងថាមានការគាំទ្រដែលអាចរកបាន នោះពួកគាត់ងាយទទួល [យកកូនធម៌ទៅថែទាំ]" ។ (អ្នកចូលរួមទី២ ឆ្នាំ២០២០)

"ដើម្បីធ្វើឱ្យ [មនុស្សម្នាក់] ក្លាយជាអ្នកថែទាំល្អ ដំបូងយើងត្រូវយកចិត្តទុកដាក់ និងគាំទ្រ ពួកគាត់ជាមុនសិន។ យើងគាំទ្រពួកគាត់នូវអ្វីដែលគាត់ត្រូវការ។ ពួកគាត់ទទួលបានវិធីព្យាបាល។ គិលានុបដ្ឋាករបស់យើងទៅជួបគាត់ជាលើកដំបូង រួចធ្វើការងារជាមួយម្ដាយធម៌។ បុគ្គលិកសង្គមដែលធ្វើការងារជាមួយគ្រួសារធម៌ តែងតែទៅជាមួយគិលានុបដ្ឋាកផងដែរ។ ហើយយើងព្យាយាមធ្វើការងារជាមួយគ្នា និងសួរថា តើគាត់មានការព្រួយបារម្ភអ្វីខ្លះ

ដែលត្រូវការការគាំទ្រពីយើង។ បែបនេះធ្វើឱ្យស្ថានភាពងាយស្រួលជាងមុន” ។(អ្នកចូលរួមទី៨ ឆ្នាំ២០២០)

អ្នកផ្តល់ព័ត៌មានស្ទើរតែទាំងអស់បានបញ្ជាក់ថា កង្វះសេវាសហគមន៍តាមប្រភេទពិការភាពជាក់លាក់ គឺជាការរាំងស្ទះដល់គ្រប់ទម្រង់ទាំងអស់នៃការថែទាំតាមគ្រួសារ។ ពីដំបូង កង្វះការគាំទ្រ និងសេវា គឺជាហេតុផលដែលឪពុកម្តាយបង្កើតបោះបង់កូនមានពិការភាពរបស់គាត់ទៅមណ្ឌលថែទាំ។ នៅពេលស្ថិតក្នុងប្រព័ន្ធថែទាំជំនួស សាច់ញាតិដែលថែទាំ ឬឪពុកម្តាយធម៌ មានភាពស្ទាក់ស្ទើរក្នុងការថែទាំកុមារមានពិការភាព ប្រសិនបើគ្មានការគាំទ្រគ្រប់គ្រាន់នោះទេ។

## ភាពភ័យខ្លាចថាការទុកដាក់ថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព មានលក្ខណៈអចិន្ត្រៃយ៍

ការថែទាំដោយឪពុកម្តាយធម៌ មានបំណងធ្វើជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ។ ការទុកដាក់ថែទាំមានរយៈពេលមួយត្រឹមកុមារត្រឡប់ទៅគ្រួសារបង្កើតរបស់គាត់វិញ ឬមានការទុកដាក់ថែទាំផ្សេងទៀតជាអចិន្ត្រៃយ៍ក្នុងគ្រួសាររបស់ឪពុកម្តាយធម៌ផ្សេងទៀត (ឧទាហរណ៍ តាមរយៈការសុំកូន) ឬនៅពេលដែលកុមារផុតអាយុថែទាំ ដែលនៅប្រទេសជាច្រើន គឺនៅអាយុ ១៨ ឆ្នាំ។

សម្រាប់កុមារដែលមានពិការភាព ទីភ្នាក់ងារថែទាំដោយឪពុកម្តាយធម៌ រកឃើញថា ឱកាសនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារបង្កើត ឬការសុំកុមារទៅចិញ្ចឹម មានកម្រិតទាបណាស់។ គ្រួសារបង្កើតមិនមានឆន្ទៈក្នុងការយកកុមារមានពិការភាពមកវិញទេ ហើយតម្រូវការសុំកុមារមានពិការភាពទៅចិញ្ចឹម មានកម្រិតទាបណាស់ (លោក ខេង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០)។ លើសពីនេះទៀត គ្រួសារធម៌ភ័យ ដែលមានសក្តានុពលខ្លាចថាកុមារមានពិការភាព អាចមិនមានភាពឯករាជ្យទេ នៅពេលដែលពួកគេពេញវ័យ ដូច្នេះហើយធ្វើឱ្យពួកគាត់មានបន្ទុកថែទាំពេញមួយជីវិត។ ចំណុចនេះ រួមផ្សំនឹងការពិតដែលថា ថ្លៃថែទាំកុមារមានពិការភាព អាចមានកម្រិតខ្ពស់ ហើយភាគច្រើននៃការថែទាំដោយឪពុកម្តាយធម៌ ត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយអង្គការក្រៅរដ្ឋាភិបាល ដែលថវិកាប្រចាំឆ្នាំមានការប្រែប្រួល ធ្វើឱ្យឪពុកម្តាយធម៌មានការភ័យខ្លាចចំពោះបន្ទុកដែលអាចកើតមាន លើសពីការទុកដាក់ថែទាំធម្មតា។

> “[ការថែទាំកុមារមានពិការភាព] នាំមកនូវការចំណាយ ដូច្នេះ [ឪពុកម្តាយធម៌] និយាយថា "ខ្ញុំអាច ប៉ុន្តែខ្ញុំត្រូវការកិច្ចសន្យាសម្រាប់ការគាំទ្ររយៈពេលវែង ព្រោះថាបើអង្គការឈប់គាំទ្រ តើខ្ញុំរស់នៅដោយរបៀបណា?" [...] ឪពុកម្តាយខ្លះរីករាយនឹងថែទាំកុមារ ប៉ុន្តែពួកគាត់គ្រាន់

> តែត្រូវការការគាំទ្រលើការចំណាយ មិនមែនតែមួយ ឬពីរឆ្នាំទេ។ កុមារទាំងនេះអាចរស់រានបានពេញមួយជីវិត។ ហើយការចំណាយបន្ថែម និងពេលវេលាដែលចំណាយក្នុងការថែទាំកុមារមានកម្រិតខ្ពស់” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “រដ្ឋាភិបាលគួរចំណាយប្រាក់ខ្លះ ព្រោះអង្គការអាចនៅដំណើរការរយៈពេលម្ភៃឆ្នាំ បន្ទាប់មកមូលនិធិត្រូវបានបញ្ឈប់ ពេលនោះឪពុកម្តាយធម៌ក៏ចាប់ផ្តើមមានសំពាធ។ ទោះបីជាពួកគាត់ស្រឡាញ់កូនក៏ដោយ តែវាជាការចំណាយបន្ថែមសម្រាប់ពួកគាត់។ រដ្ឋាភិបាលគួរគាំទ្រដល់ពួកគាត់” ។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

ការធ្វើផែនការអចិន្ត្រៃយ៍ មានភាពលំបាកសម្រាប់កុមារមានពិការភាព។ ក្នុងករណីខ្លះ ដោយសារអង្គការក្រៅរដ្ឋាភិបាលដែលដំណើរការកម្មវិធីថែទាំដោយឪពុកម្តាយធម៌ មានកម្មវិធីរយៈពេលខ្លី ដែលមានពេលតែមួយ ឬពីរឆ្នាំប៉ុណ្ណោះ។ ហើយទីពីរ ដោយសារតែការលំបាកក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍ដើម្បីទុកដាក់កុមារមានពិការភាព ដោយសារការមាក់ងាយជុំវិញពិការភាព និងធនធានចាំបាច់សម្រាប់ថែទាំកុមារមានពិការភាព។

> “សម្រាប់កុមារមានពិការភាព វានៅតែជាបញ្ហាប្រឈម។ [...] ការស្វែងរកគ្រួសារអចិន្ត្រៃយ៍សម្រាប់ពួកគាត់គឺជាការលំបាក ដោយសារអង្គការក្រៅរដ្ឋាភិបាលមិនមានផែនការអចិន្ត្រៃយ៍សម្រាប់ពួកគាត់ សម្រាប់ករណីនីមួយៗ” ។ (អ្នកចូលរួមទី៥ ឆ្នាំ២០២០)

ក្នុងករណីភាគច្រើន ឪពុកម្តាយធម៌មានការរំពឹងទុកថា កូនធម៌នឹងផុតអាយុថែទាំ រួចមានភាពឯករាជ្យនៅពេលណាមួយក្នុងជីវិត។ ចំពោះកុមារដែលមានពិការភាពធ្ងន់ធ្ងរ ចំណុចនេះមិនទំនងជាកើតឡើងនោះទេ។ បើគ្មានផែនការអចិន្ត្រៃយ៍ត្រឹមត្រូវទេ ឪពុកម្តាយធម៌អាចភ័យខ្លាចថា ពួកគាត់កំពុងទទួលយកការថែទាំពេញមួយជីវិត ប្រសិនបើពួកគាត់ទទួលយកកុមារទៅផ្ទះរបស់ខ្លួន។

> “ប្រសិនបើការថែទាំដោយឪពុកម្តាយធម៌ មានលក្ខណៈបណ្តោះអាសន្ន នោះកុមារដែលរស់នៅក្នុងគ្រួសារធម៌ គួរទទួលបានការបង្ហាត់អំពីអ្វីដែលនឹងកើតឡើងបន្ទាប់ពីនោះ។ ពួកគាត់គួរត្រូវបានបង្ហាត់ថា វាជាការថែទាំបណ្តោះអាសន្ន គឺមិនមែនអចិន្ត្រៃយ៍ទេ។ ការមានយុទ្ធសាស្ត្រចាកចេញ គឺមានសារសំខាន់នៅពេលចាប់ផ្តើមការទុកដាក់ថែទាំក្នុងគ្រួសារធម៌។ [...] ហេតុដូច្នេះហើយ យើងពិបាកស្រមៃថា ជនមានពិការភាពធ្ងន់ធ្ងរ និងមានពិការភាពច្រើនប្រភេទ ត្រូវបានទុកដាក់ថែទាំឱ្យបានល្អត្រឹមត្រូវក្នុងគ្រួសារធម៌ ដោយសារតែពួកគាត់នឹងមិនបានត្រៀមរួចរាល់សម្រាប់ [មានភាពឯករាជ្យ] ទាំងរាងកាយ និងបញ្ញា"។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០) ។



# កត្តាជំរុញការរួមបញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌

## លើកកម្ពស់ការយល់ដឹងអំពីពិការភាព ដើម្បីបង្កើនចំណេះដឹង និងលុបបំបាត់ជំនឿមិនពិត

កង្វះការយល់ដឹងអំពីពិការភាព និងថាតើវាលំបាកយ៉ាងណាសម្រាប់ជីវិតរបស់កុមារ គឺជាកត្តាដ៏ធំមួយដែលឪពុកម្តាយបង្កើតបោះបង់ចោលកូនរបស់ខ្លួន ហើយវាក៏ជាកត្តាមួយដែលធ្វើឱ្យឪពុកម្តាយធម៌មិនសូវចាប់អារម្មណ៍ក្នុងការថែទាំកុមារដែលមានពិការភាពផងដែរ។ ការងារលើកកម្ពស់ការយល់ដឹងអំពីពិការភាព ការលុបបំបាត់ជំនឿមិនពិត និងការបើកចំហចំពោះតម្រូវការថែទាំនាពេលបច្ចុប្បន្ន និងការរំពឹងទុកនាពេលអនាគត (បរិយាបន្ន) អាចជាកត្តាដ៏ធំមួយក្នុងការរួមបញ្ចូលកុមារមានពិការភាពទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌។ នេះមានន័យថា ការបង្កើនការយល់ដឹងនៅក្នុងសហគមន៍ ក្នុងចំណោមថ្នាក់ដឹកនាំ និងក្នុងចំណោមបុគ្គលិកសង្គម។

> “[មាន] ការចាំបាច់មួយដែលត្រូវ លើកកម្ពស់ការយល់ដឹងក្នុងសហគមន៍។ ធ្វើដូច្នេះគឺដើម្បីកុំឱ្យឪពុកម្តាយបោះបង់កូនចោលតាំងពីដំបូងទៅ” ។ (អ្នកចូលរួមទី១ ឆ្នាំ២០២០)

> “ការរើសអើងបែបនោះនៅតែមាននៅក្នុងសហគមន៍របស់យើង។ លុះត្រាតែពួកគាត់យល់ច្បាស់ពីអ្វីដែលត្រូវធ្វើចំពោះកុមារមានពិការភាព ហើយពួកគាត់ទទួលបានការគាំទ្រត្រឹមត្រូវព្រមទាំងទទួលបានការអប់រំ នោះទើបពួកគាត់មានឆន្ទៈទទួលយកកុមារទាំងនោះ” ។ (អ្នកចូលរួមទី៥ ឆ្នាំ២០២០)

## ការទទួលសេវាតាមប្រភេទពិការភាពជាក់លាក់ នៅក្បែរផ្ទះឪពុកម្តាយធម៌

ដើម្បីធានាថាកុមារមានពិការភាព មានឱកាសខ្ពស់ក្នុងការស្វែងរកការថែទាំដោយឪពុកម្តាយធម៌ ជាជាងការទុកដាក់នៅមណ្ឌលថែទាំ នោះសេវាតាមប្រភេទពិការភាពជាក់លាក់នៅក្បែរផ្ទះឪពុកម្តាយធម៌ គឺជាចំណុចដ៏សំខាន់។ សេវាតាមប្រភេទពិការភាពជាក់លាក់ អាចជួយគ្រួសារ(ធម៌) ឱ្យយល់អំពីតម្រូវការរបស់កូន ហើយធ្វើឱ្យពួកគាត់វិនិយោគទៅលើការរីកចម្រើនរបស់កុមារ។

> “បើអ្នកចង់បង្កើនចំនួនកុមារមានពិការភាព [នៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្ដាយធម៌] អ្នកត្រូវចាប់ផ្ដើមដោយការរកមើលថា តើធនធាន [សម្រាប់កុមារមានពិការភាព ដូចជាការស្ដារនីតិសម្បទា] ដែលមានស្រាប់មាននៅទីណា រួចកសាងនៅទីនោះ។ បន្ទាប់មកអ្នកអាចទុកដាក់កុមារនៅក្នុងតំបន់ទាំងនោះបាន” ។ (អ្នកចូលរួមទី២ ឆ្នាំ២០២០)

ការមានសេវាគាំទ្រតាមប្រភេទពិការភាពជាក់លាក់ស្ថិតនៅក្នុងបរិវេណជិតនោះ ក៏នឹងជួយកាត់បន្ថយថ្លៃដឹកជញ្ជូនដែលអង្គការដែលធ្វើការទៅលើការថែទាំដោយឪពុកម្ដាយធម៌ ត្រូវចំណាយផងដែរ។ ដូចដែលបានចែករំលែកដោយអង្គការកុមារនៅក្នុងគ្រួសារថា "ដោយសារតែទីតាំងរស់នៅរបស់កុមារមានច្រើនកន្លែង យើងត្រូវចំណាយច្រើនគួរសមទៅលើការធ្វើដំណើរ សម្រាប់កុមារទៅទទួលសេវាព្យាបាលសុខភាព ឬសេវាផ្សេងៗផង និងសម្រាប់បុគ្គលិករបស់យើងផងដែរ។ វាអាចផ្ដល់ការសន្សំមួយចំនួនសម្រាប់អង្គការដទៃទៀត ប្រសិនបើកន្លែងទុកដាក់ថែទាំកុមាររបស់ពួកគាត់ស្ថិតនៅក្បែរសេវាចាំបាច់ទាំងនោះ។

ការមានសេវានៅក្បែរដើម្បីជួយគាំទ្រដល់កុមារមានពិការភាព ផ្ដល់អត្ថប្រយោជន៍មួយចំនួន។ ទីមួយ ជំនាញរបស់កុមារមានភាពប្រសើរឡើង ធ្វើឱ្យកុមារមានសមត្ថភាពកើនឡើងក្នុងការប្រាស្រ័យទាក់ទង និងការចូលរួម។ ទីពីរ ការដែលគាត់ដឹងថាពួកគាត់មិនឯកា ហើយមានចំណេះដឹងត្រឹមត្រូវក្នុងការថែទាំកុមារ នោះវានឹងកាត់បន្ថយភាពភ័យខ្លាច(ដែលអាចមាន) របស់ឪពុកម្ដាយចំពោះការទទួលយកកុមារមានពិការភាពមកថែទាំផងដែរ។

> “នៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្ដាយធម៌របស់យើង ពីដំបូងយើងពិបាកស្វែងរកឪពុកម្ដាយធម៌រយៈពេលខ្លី សម្រាប់កុមារទាំងនោះ។ ពួកគាត់មានអារម្មណ៍ថាគាត់គ្មានជំនាញ។ [...] ប៉ុន្តែច្រើនឆ្នាំក្រោយមក និងបន្ទាប់ពីការបណ្ដុះបណ្ដាលមួយចំនួន ពួកគាត់ក៏ស៊ាំទៅ នឹងការងារទាំងនេះយ៉ាងងាយស្រួល ហើយពួកគាត់ក៏លង់ស្រលាញ់កុមារទាំងនោះ។ បន្ទាប់មកពួកគាត់ក៏ចង់ថែទាំកុមារ” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “សម្រាប់ការថែទាំដោយឪពុកម្ដាយធម៌ យើងត្រូវការសេវាទាំងនោះសម្រាប់កុមារមានពិការភាព ដើម្បីឱ្យកុមារធំលូតលាស់នៅក្នុងបរិយាកាសគ្រួសារ” ។ (អ្នកចូលរួមទី៩ ឆ្នាំ២០២០)

ពួកគាត់ខ្វះចំណេះដឹង និងជំនាញក្នុងការថែទាំកុមារមានពិការភាព។ ដូច្នេះពួកគាត់មើលឃើញថាកុមារមានពិការភាព គឺជាបន្ទុកដ៏ធំសម្រាប់គ្រួសារ។ [...] ពួកគាត់ស្រឡាញ់កុមារ ប៉ុន្តែវាត្រូវការជំនាញ និងសមត្ថភាពយ៉ាងច្រើន ដើម្បីថែទាំកុមារ។ ដូច្នេះនៅពេលបានកសាងសមត្ថភាពរួច ពួកគាត់មានអារម្មណ៍ថាវាមានប្រយោជន៍ជាខ្លាំងសម្រាប់គាត់” ។ (អ្នកចូលរួមទី៥ ឆ្នាំ២០២០)

# ការផ្តល់ ការថែទាំ ដើម្បីមានពេលសម្រាកដល់គ្រួសារធម៌

ឪពុកម្តាយធម៌ដែលទទួលថែទាំកុមារដែលមានពិការភាព(ធ្ងន់ធ្ងរ) ត្រូវការការថែទាំដើម្បីសម្រាកក្នុងរយៈពេលមួយ ដើម្បីអាចមើលថែកុមារមានពិការភាពនៅក្នុងផ្ទះរបស់គាត់។ ការថែទាំ ដើម្បីមានពេលសម្រាក ដូចជាការថែទាំពេលថ្ងៃ ឬការថែទាំចុងសប្តាហ៍ អាចផ្តល់ការសម្រាកដល់ឪពុកម្តាយធម៌ ហើយធ្វើឱ្យការទុកដាក់ថែទាំកុមារកាន់តែមានស្ថិរភាព (EveryChild, 2011)។

> “យើងក៏គិតផងដែរថា វាប្រហែលជាមានភាពតានតឹងសម្រាប់គ្រួសារធម៌។ ដូច្នេះយើងកំពុងជ្រើសរើសអាណាព្យាបាលបន្ថែម ដែលអាចមើលថែកុមារនៅចុងសប្តាហ៍ ឬក៏ពេលខ្លះ។ ដូច្នេះឪពុកម្តាយធម៌អាចមានពេលសម្រាកខ្លះ យ៉ាងហោចណាស់ក៏បានពេលសម្រាកក្រៅម៉ោងមួយផ្នែកដែរ” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

ការថែទាំកុមារមានពិការភាព ជាពិសេសកុមារដែលមានតម្រូវការថែទាំខ្ពស់ អាចផ្តល់ភាពតានតឹងដល់ឪពុកម្តាយធម៌ ព្រមទាំងត្រូវចំណាយពេលយ៉ាងច្រើន។ វាអាចមានន័យថា អ្នកថែទាំមិនអាចចាកចេញពីផ្ទះដើម្បីទៅជួបមនុស្សខាងក្រៅ ឬព្រឹត្តិការណ៍សហគមន៍ផ្សេងៗ ឬមិនអាចផ្តល់ការយកចិត្តទុកដាក់មួយទល់មួយដល់កុមារផ្សេងទៀត។ ក្នុងករណីខ្លះ អ្នកថែទាំក៏មិនអាចសុំឱ្យសមាជិកគ្រួសារ ឬមិត្តភក្តិ ជួយមើលថែកុមារមានពិការភាពបានទៀត ព្រោះការថែទាំនោះអាចនឹងត្រូវការកម្រិតជំនាញជាក់លាក់មួយ។

បច្ចុប្បន្ននៅប្រទេសកម្ពុជា គេមិនសូវដឹងពីការថែទាំដើម្បីមានពេលសម្រាក ដែលជាលក្ខណៈផ្លូវការនោះទេ។ ទោះជាយ៉ាងនេះក្តី ការដែលអាចសម្រាកពីការថែទាំកុមារ បានបង្ហាញថា អាចកាត់បន្ថយភាពតានតឹង និងបង្កើនគុណភាពជីវិតរបស់អ្នកថែទាំកុមារមានពិការភាពពិតប្រាកដមែន។ ការមានប្រព័ន្ធថែទាំដើម្បីសម្រាក ដើម្បីអនុញ្ញាតឱ្យអ្នកថែទាំបានសម្រាក ហើយវិនិយោគលើសកម្មភាពសង្គម និងសហគមន៍ នឹងបង្កើនឱកាសជោគជ័យក្នុងការទុកដាក់ថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព (Jenny et al., n.d.)។

# ការកំណត់អត្តសញ្ញាណយ៉ាងត្រឹមត្រូវ និងការធ្វើផែនការអចិន្ត្រៃយ៍

ការកំណត់អត្តសញ្ញាណយ៉ាងត្រឹមត្រូវ អាចនាំឱ្យមានភាពប្រសើរឡើងនូវការថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព។ ប្រសិនបើបុគ្គលិកសង្គម យល់អំពីពិការភាព នោះពួកគាត់អាចកត់សម្គាល់កាន់តែប្រសើរអំពីតម្រូវការរបស់កុមារ រួចផ្គូផ្គងកុមារទៅនឹងគ្រួសារសមស្របមួយដែលយល់អំពីតម្រូវការរបស់កុមារ។

> “បញ្ហាមួយដែលយើងបានឃើញគឺថា អង្គការដែលធ្វើការលើការថែទាំដោយឪពុកម្តាយធម៌ មិនយល់អំពីអ្វីជាតម្រូវការពិសេសនោះទេ។ កុមារនៅក្នុងការថែទាំរបស់ពួកគាត់ មិនទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់នោះឡើយ” ។ (អ្នកចូលរួមទី៤ ឆ្នាំ២០២០)

ការកំណត់អត្តសញ្ញាណកុមារមានពិការភាពបានត្រឹមត្រូវ មានគោលបំណងជាច្រើនយ៉ាង។ ទីមួយ វាអនុញ្ញាតឱ្យអនាគតឪពុកម្តាយធម៌ យល់ពីអ្វីដែលជាការរំពឹងទុករបស់កុមារ ក៏ដូចជាតម្រូវការនៃការថែទាំផងដែរ។ បន្ទាប់មក ពួកគាត់អាចធ្វើការវាយតម្លៃបានល្អប្រសើរ ថាតើគាត់ចង់ទទួលយកកុមារឬក៏អត់ ហើយវានឹងកាត់បន្ថយឱកាសនៃភាពខកចិត្តក្នុងការទុកដាក់ថែទាំកុមារ ព្រមទាំងតម្រូវការក្នុងការបញ្ជូនកុមារទៅកន្លែងទុកដាក់ថែទាំថ្មីទៀតនៅពេលក្រោយ។

> “កុមារដែលនឹងទទួលបានអត្ថប្រយោជន៍ពីការថែទាំដោយឪពុកម្តាយធម៌ គួរត្រូវបានកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ ដើម្បីស្វែងយល់អំពីតម្រូវការចាំបាច់ រួចរៀបចំផែនការកម្មវិធីថែទាំដោយឪពុកម្តាយធម៌ ដោយប្រើធនធាន និងថវិកាសមរម្យ។ ឈរលើមូលដ្ឋាននេះ ឪពុកម្តាយធម៌គួរត្រូវបានជ្រើសរើស បណ្តុះបណ្តាល និងគាំទ្រ ដើម្បីបំពេញតម្រូវការរបស់កុមារ។ (Jenny et al., n.d., p. 21)

ទី២ ប្រសិនបើពិការភាពត្រូវបានកត់សម្គាល់យ៉ាងត្រឹមត្រូវ នោះឪពុកម្តាយធម៌ អាចទទួលបានការគាំទ្រសមស្រប បើចាំបាច់ រួមមានការបណ្តុះបណ្តាល ការព្យាបាល ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការថែទាំដើម្បីមានពេលសម្រាក និងការថែទាំវេជ្ជសាស្ត្រ។ ចុងក្រោយ ជាមួយនឹងការកំណត់អត្តសញ្ញាណ និងការវាយតម្លៃយ៉ាងត្រឹមត្រូវ កុមារអាចត្រូវបានបញ្ជូនទៅរកសេវាតាមពិការភាពជាក់លាក់។ លទ្ធភាពទទួលបានការព្យាបាល និងសេវាវេជ្ជសាស្ត្រ ធ្វើឱ្យសមត្ថភាពរបស់កុមារបានប្រសើរឡើង ហើយផ្តល់លទ្ធផលត្រឡប់មកវិញ ដោយបង្កើនអាកប្បកិរិយាវិជ្ជមានរបស់អ្នកថែទាំចំពោះកុមារដែលស្ថិតក្នុងការថែទាំរបស់គាត់។

ក្នុងគំនិតជាមួយគ្នានេះដែរ នៅពេលដែលកុមារត្រូវបានកំណត់អត្តសញ្ញាណ និងវាយតម្លៃបានគ្រប់គ្រាន់ នោះចាំបាច់ត្រូវមានផែនការអចិន្ត្រៃយ៍ដ៏ត្រឹមត្រូវមួយ ដែលជាផ្នែកមួយនៃដំណើរការផងដែរ។ កិច្ចការនេះរួមបញ្ចូលទាំងការងារជាមួយឪពុកម្តាយបង្កើត ដើម្បីមើលថាតើសមាហរណកម្មអាចធ្វើទៅរួចដែរឬទេ។

> “ការថែទាំដោយឪពុកម្តាយធម៌ គឺជាគំនិតថ្មីមួយសម្រាប់ប្រជាជនទូទៅ។ មិនមានគ្រួសារច្រើនទេដែលយល់ពីន័យរបស់វា។ តើខ្ញុំសុំកូនម្នាក់នេះមកធ្វើជាកូនរបស់ខ្ញុំមែនទេ? តើកូននេះនឹងស្នាក់នៅជាមួយខ្ញុំរៀងរហូតឬ?” (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

ការយល់ដឹងអំពីពេលវេលានៃការទុកដាក់ថែទាំ ក៏ជួយដល់ឪពុកម្តាយធម៌ផងដែរ ក្នុងការសម្រេចចិត្ត ដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ ថាតើគួរទទួលថែទាំកុមារម្នាក់នោះដែរឬទេ។ បច្ចុប្បន្ននេះ មនុស្សជាច្រើនប្រហែលជាភ័យខ្លាចក្នុងការទទួលយកកុមារមានពិការភាព ព្រោះពួកគាត់ខ្លាចថាកុមារនឹងស្ថិតក្នុងការមើលថែរបស់គាត់ជារៀងរហូត៖ កុមារមិនអាចវិលត្រឡប់ទៅផ្ទះវិញទេ ព្រោះកុមារមានពិការភាព ពិបាកនឹងធ្វើសមាហរណកម្មក្នុងគ្រួសារបង្កើតរបស់គេវិញណាស់។ មនុស្សជាច្រើនទៀតប្រហែលជាបារម្ភថានឹងជាប់បន្ទុកហិរញ្ញវត្ថុ ព្រោះថវិការបស់អង្គការក្រៅរដ្ឋាភិបាល អាចនឹងកាត់ផ្តាច់នៅពេលណាមួយ។ ការយល់ច្បាស់តាំងពីដំបូង អំពីរយៈពេលនៃការទុកដាក់ថែទាំ និងការពិភាក្សាជាប្រចាំអំពីផែនការយូរអង្វែងសម្រាប់កុមារម្នាក់ៗ អាចលុបបំបាត់ភាពភ័យខ្លាច ព្រមទាំង ផ្តល់ការគាំទ្រដល់ឪពុកម្តាយធម៌ក្នុងពេលដែលពួកគាត់ថែទាំកុមារមានពិការភាព។

## ការរ៉ាប់រងថ្លៃចំណាយយ៉ាងគ្រប់គ្រាន់

កុមារមានពិការភាពអាចនាំឱ្យមានការចំណាយខ្ពស់ជាងកុមារដែលមិនមានពិការភាព (Palmer, Williams, & McPake, 2016) ហើយការរ៉ាប់រងថ្លៃចំណាយយ៉ាងត្រឹមត្រូវ និងប្រកបដោយស្ថិរភាពសម្រាប់គ្រួសារធម៌ នឹងបង្កើនឱកាសនៃការទុកដាក់ថែទាំយ៉ាងត្រឹមត្រូវ។

> “[ការបារម្ភពីការចំណាយ] គឺជាបញ្ហាប្រឈម និងកត្តារារាំងដ៏ធំមួយ។ ឪពុកម្តាយខ្លះរីករាយក្នុងការថែទាំកុមារ ប៉ុន្តែគ្រាន់តែត្រូវការការគាំទ្រលើថ្លៃចំណាយប៉ុណ្ណោះ ហើយសម្រាប់ពេលយូរអង្វែង គឺមិនមែនត្រឹមតែមួយ ឬពីរឆ្នាំនោះទេ។ កុមារទាំងនេះអាចរស់រានពេញមួយជីវិត ហើយការចំណាយបន្ថែមព្រមទាំងពេលវេលាដែលពួកគាត់ត្រូវការ ដើម្បីថែទាំកុមារនឹងមានកម្រិតខ្ពស់ណាស់” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

ដូចបានបញ្ជាក់ពីក្រសួងសង្គមកិច្ចដូច្នេះថា “គ្រួសារធម៌ដែលថែទាំកុមារមានពិការភាព គួរទទួលបានប្រាក់សំណង ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃដល់កុមារ៖ រាល់ថ្លៃចំណាយវេជ្ជសាស្ត្រ និងថ្លៃថែទាំទាំងអស់ គួរតែជាការរ៉ាប់រងរបស់រដ្ឋ។ ប្រាក់សំណងដែលផ្តល់ជូនគ្រួសារធម៌ អាចជារបៀបមួយដែលយើងផ្តល់តម្លៃដល់ពួកគាត់ក្នុងនាមជាអ្នកមានវិជ្ជាជីវៈ” ។ (Jenny et al., n.d., p. 22) ។ ជាការប្រសើរ ប្រាក់សំណងនេះគួរផ្តល់ជូនដោយរដ្ឋ ព្រោះអង្គការក្រៅរដ្ឋាភិបាលច្រើនតែពឹងផ្អែកលើមូលនិធិពីខាងក្រៅដែលអាចនាំឱ្យមានភាពស្រពេចស្រពិល ថាតើថវិកាមានរយៈពេលយូរប៉ុណ្ណា។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ននេះប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ រួមទាំងការផ្តល់មូលនិធិ នៅពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាលនៅឡើយ (លោក ខេង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០)។

“ការរ៉ាប់រងចុងក្រោយគួរតែជារដ្ឋាភិបាល មិនមែនជាអង្គការទេ។ ខ្ញុំគិតថា បែបនេះនឹងលើកទឹកចិត្តឱ្យគ្រួសារជាច្រើនទទួលថែទាំកុមារថែមទៀត មិនមែនដោយសារតែពួកគាត់អាចរកប្រាក់ចំណូលបាននោះទេ ប៉ុន្តែដោយសារតែគាត់មិនចាំបាច់ចំណាយប្រាក់” ។ (អ្នកចូលរួមទី៧ ឆ្នាំ២០២០)

## ចំណេះដឹង និងការយល់ដឹងអំពីជម្រើសផ្សេងៗនៃការថែទាំជំនួស

ដូចដែលបានកត់សម្គាល់ពីខាងដើមនៅក្នុងរបាយការណ៍នេះ មានជំនឿជាទូទៅមួយ គឺថា មណ្ឌលថែទាំកុមារ គឺជាកន្លែងដ៏ប្រសើរបំផុតសម្រាប់កុមារមានពិការភាព ដោយសារពួកគេជឿថា កន្លែងនោះមានជំនាញឯកទេសចាំបាច់ ដើម្បីថែទាំកុមារមានពិការភាព។ ការផ្តល់ចំណេះដឹង និងព័ត៌មានអំពីលទ្ធភាពនៃការថែទាំកុមារមានពិការភាពនៅក្នុងគ្រួសារ មិនថាជាកូនបង្កើត ឬជាកូនធម៌ទេ អាចជាកត្តាដ៏សំខាន់មួយក្នុងការបង្ហាញថា មានជម្រើសជំនួសផ្សេងៗទៀតសម្រាប់កុមារដែលមានពិការភាពដែរ។

"មណ្ឌលថែទាំកុមារមានការទទួលស្គាល់ច្រើននៅក្នុងសហគមន៍របស់ពួកគាត់ ហើយអាចមើលឃើញ និងរកបានដោយងាយស្រួល។ ទោះជាយ៉ាងនេះក៏ដោយ នៅពេលដែលមន្ត្រីបានយល់ពីទម្រង់នៃការ ថែទាំជំនួសផ្សេងៗ នោះអាកប្បកិរិយាអាចនឹងផ្លាស់ប្តូរទៅរកការលើកកម្ពស់ទម្រង់នៃការថែទាំជំនួសតាមគ្រួសារ និងតាមសហគមន៍វិញ” ។ (UNICEF, 2011, p. 46)

"ហើយនៅពេលអ្នកស្តាប់ឮកាន់តែច្រើនអំពី [មណ្ឌលថែទាំកុមារ] នោះពួកគាត់កាន់តែគិតថា វាមិនអីទេ រួចគ្រាន់តែបញ្ជូនកូនរបស់ខ្លួនទៅមណ្ឌលថែទាំកុមារតែម្តង” ។ (អ្នកចូលរួមទី៩ ឆ្នាំ២០២០)

នៅពេលដែលប្រជាជន និងអាជ្ញាធរ មើលមិនឃើញថាការថែទាំដោយឪពុកម្តាយធម៌ ជាជម្រើសជំនួសដែលមានប្រសិទ្ធភាពសម្រាប់កុមារមានពិការភាពទេ នោះពួកគេនឹងមិនបញ្ជូនកុមារទៅទីនោះឡើយ។ ប្រសិនបើមានការយល់ដឹងបន្ថែមអំពីការពិតដែលថាកុមារមានពិការភាព អាចទទួលការថែទាំដោយឪពុកម្តាយធម៌ដែរ ឬថាកុមារមិនចាំបាច់ត្រូវតែទៅមណ្ឌលថែទាំដោយស្វ័យប្រវត្តិនោះទេ នោះជម្រើសផ្សេងៗទៀតនៃការថែទាំជំនួស ទំនងជានឹងលើកមកពិចារណានៅពេលចាំបាច់។

មធ្យោបាយមួយដើម្បីលើកកម្ពស់ការយល់ដឹង គឺគ្រាន់តែចាប់ផ្តើមជាមួយគ្រួសារមួយចំនួនដែលថែទាំកុមារមានពិការភាព។

> “ពីដំបូងមានគ្រួសារមួយ ឬពីរ បានទទួលយក ហើយអ្នកជិតខាងដែលនៅជុំវិញមើលឃើញថានេះ គឺជាឱកាសដើម្បីថែទាំក្មេងៗ” ។ (អ្នកចូលរួមទី៣ ឆ្នាំ២០២០)

> “មានមនុស្សដែលមានគំនិតផ្សេងពីគ្នា ហើយប្រសិនបើអ្នករកពួកគាត់ឃើញ នោះវានឹងជួយផ្លាស់ប្តូរទស្សនៈនៅក្នុងសហគមន៍។ ប៉ុន្តែនៅពេលអ្នកចាប់ផ្តើមជាមួយគ្រួសារពីរបី បន្ទាប់មកគ្រួសារផ្សេងៗទៀតពិតជាចាប់ផ្តើមពិចារណាទទួលយកវា” ។ (អ្នកចូលរួមទី២ ឆ្នាំ២០២០)

នៅពេលអ្នកជិតខាង និងសហគមន៍មើលឃើញថាកុមារមានពិការភាព អាចត្រូវបានថែទាំ និងលូតលាស់ នោះពួកគេអាចនឹងយល់ថា មណ្ឌលថែទាំកុមារមិនមែនជាជម្រើសតែមួយមុខសម្រាប់កុមារមានពិការភាពនោះទេ។

# សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវទូទាំងពិភពលោកបង្ហាញថា កុមារមានពិការភាពទំនងជាមិនសូវស្ថិតក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌នោះទេ ទោះបីជាពួកគាត់អាចនឹងត្រូវការប្រើប្រាស់ប្រព័ន្ធថែទាំជំនួសដូចគ្នាដែរ នៅពេលដែលមិនអាចស្នាក់នៅជាមួយគ្រួសារបង្កើតបាន។ ស្ថានភាពនេះ គឺដូចគ្នានៅប្រទេសកម្ពុជាផងដែរ។ ការសិក្សានេះ គឺជាការសង្កេតមើលជាលើកដំបូង ទៅលើអ្វីដែលជាកត្តារារាំង និងអ្វីជាកត្តាជំរុញ នៅពេលនិយាយអំពីការថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាពនៅប្រទេសកម្ពុជា។

តាមរយៈការសិក្សាលើអត្ថបទដែលមានស្រាប់នានា និងកិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួន យើងបានកំណត់ឃើញនូវកត្តារារាំងសំខាន់ៗចំនួន ៦ និងកត្តាជំរុញចំនួន ៦ផងដែរ ចំពោះការថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព។

កត្តារារាំងរួមមាន ៖

- ការភ័យខ្លាច និងការយល់ច្រឡំអំពីពិការភាព
- ការយល់ឃើញរបស់មណ្ឌលថែទាំកុមារមានពិការភាព
- អសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណកុមារមានពិការភាព និងតម្រូវការរបស់ពួកគេឱ្យបានច្បាស់លាស់
- កង្វះការត្រៀមលក្ខណៈ និងការគាំទ្រគ្រប់គ្រាន់ទៅដល់ឪពុកម្តាយធម៌
- កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់
- ភាពភ័យខ្លាចថាការទុកដាក់ថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានពិការភាព មានលក្ខណៈអចិន្ត្រៃយ៍

កត្តាជំរុញរួមមាន ៖

- លើកកម្ពស់ការយល់ដឹងអំពីពិការភាព ដើម្បីបង្កើនចំណេះដឹង និងលុបបំបាត់ជំនឿមិនពិត
- ការទទួលសេវាតាមប្រភេទពិការភាពជាក់លាក់ នៅក្បែរផ្ទះឪពុកម្តាយធម៌
- ការផ្តល់ការថែទាំ ដើម្បីមានពេលសម្រាក ដល់គ្រួសារធម៌
- ការកំណត់អត្តសញ្ញាណយ៉ាងត្រឹមត្រូវ និងការធ្វើផែនការអចិន្ត្រៃយ៍
- ការរ៉ាប់រងថ្លៃចំណាយយ៉ាងគ្រប់គ្រាន់
- ចំណេះដឹង និងការយល់ដឹងអំពីជម្រើសផ្សេងៗនៃការថែទាំជំនួស

ចំណុចគួរឱ្យចាប់អារម្មណ៍ដែរគឺថា កត្តារារាំង និងកត្តាជំរុញជាច្រើននៃការថែទាំដោយឪពុកម្តាយធម៌ ក៏ជាបញ្ហាដែលត្រូវដោះស្រាយផងដែរ ដើម្បីកាត់បន្ថយតម្រូវការនៃការថែទាំជំនួស។ ការយល់ច្រឡំ អំពីពិការភាព កង្វះការគាំទ្រដល់ឪពុកម្តាយ កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាព ជាក់លាក់ ការរ៉ាប់រងថ្លៃចំណាយគ្រប់គ្រាន់សម្រាប់អ្នកថែទាំ... ទាំងនេះ គឺជាហេតុផលដែលឪពុកម្តាយបង្កើតបោះបង់ការថែទាំកូនដែលមានពិការភាព រួចទុកដាក់កូននៅក្នុងប្រព័ន្ធថែទាំជំនួស។ ចំណុចនេះត្រូវបានលើកឡើងដោយអ្នកផ្តល់ព័ត៌មានផងដែរ ដោយលើកឡើងថា "ផ្នែកមួយនៃតម្រូវការសម្រាប់ការថែទាំជំនួស [សម្រាប់កុមារមានពិការភាព] គឺដោយសារតែកង្វះសេវាដើម្បីជួយគាំទ្រដល់គ្រួសារ ដែលនាំទៅដល់ការបោះបង់កុមារ" (អ្នកចូលរួមទី២ ឆ្នាំ២០២០) ។

ប្រសិនបើយើងអាចដោះស្រាយបញ្ហាទាំងនេះ ដោយមានគោលដៅកែលម្អបរិយាបន្ននៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ នោះក្នុងពេលតែមួយ គឺពួកយើងក៏ធ្វើការងារដើម្បីបង្ការការបំបែកចេញពីគ្រួសារតាំងពីជំហ៊ានដំបូង។

## អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម

របាយការណ៍នេះ ចាប់ផ្តើមដោយការស្វែងរកនូវកត្តារារាំង និងកត្តាជំរុញការដាក់បញ្ចូលកុមារមានពិការភាព ទៅក្នុងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ នៅប្រទេសកម្ពុជា។ ខាងក្រោមនេះ គឺជាអនុសាសន៍មួយចំនួន សម្រាប់ការស្រាវជ្រាវបន្ថែម ដើម្បីបន្តការសិក្សាអំពីវិធីល្អបំផុតក្នុងការគាំទ្រសមាហរណកម្មកុមារមានពិការភាពទៅក្នុងការថែទាំតាមគ្រួសារវិញ។

## ឥទ្ធិពលនៃសេវាតាមប្រភេទពិការភាពជាក់លាក់ ទៅលើការថែទាំជំនួសសម្រាប់កុមារមានពិការភាព

លទ្ធផលមួយនៃការសិក្សានេះគឺថា ឪពុកម្តាយធម៌របស់កុមារមានពិការភាព និងកុមារមានពិការភាពខ្លួនឯង មិនអាចធ្វើតែម្នាក់ឯងបានទេ។ ចាំបាច់ត្រូវមានការគាំទ្រត្រឹមត្រូវ - មិនថាក្នុងទម្រង់ជាការថែទាំវេជ្ជសាស្ត្រ សេវាព្យាបាល ឧបករណ៍ជំនួយ ឬការថែទាំ ដើម្បីមានពេលសម្រាកនោះទេ។ កង្វះលទ្ធភាពទទួលបានសេវាតាមប្រភេទពិការភាពជាក់លាក់ ត្រូវបានគេមើលឃើញថាជាឧបសគ្គដ៏ធំមួយក្នុងការថែទាំកុមារមានពិការភាពដោយឪពុកម្តាយធម៌ ហើយក៏អាចជាហេតុផលមួយដែលឪពុកម្តាយបង្កើតបោះបង់កូនរបស់ខ្លួនទៅទុកដាក់ក្នុងប្រព័ន្ធថែទាំជំនួសផងដែរ។ ដូច្នេះ តំបន់ស្រាវជ្រាវបន្ថែមទៀត គឺការសិក្សាថា តើមានទំនាក់ទំនងដោយផ្ទាល់រវាងសេវាតាមប្រភេទពិការភាពជាក់លាក់/ សេវាស្តារនីតិសម្បទាតាមសហគមន៍ ជាមួយនឹងចំនួនកុមារមានពិការភាពដែលត្រូវបាន

បោះបង់ទៅទុកដាក់ក្នុងការថែទាំជំនួស និង/ឬទុកដាក់ក្នុងប្រព័ន្ធថែទាំដោយឪពុកម្ដាយធម៌ ដែរឬទេ។

## ពលកម្មកុមារជាកត្តារារាំង ឬកត្តាជំរុញនៃការថែទាំដោយឪពុកម្ដាយធម៌

ថ្វីត្បិតមិនសូវមានការរាយការណ៍ពិតមែន តែជួនកាលការថែទាំដោយឪពុកម្ដាយធម៌ កើតឡើងដើម្បីបំពេញតម្រូវការកម្លាំងពលកម្មនៅក្នុងគ្រួសារធម៌ (Webbink, Smits, & Jong, 2010) ។ ទាំងអត្ថបទសិក្សាដែលមានស្រាប់ និងអ្នកផ្ដល់ព័ត៌មាន មិនបានលើកឡើងពីកម្លាំងពលកម្មនៅក្នុងការសិក្សានេះទេ ប៉ុន្តែបុគ្គលិកអង្គការ Light for the World បានបង្ហាញភស្តុតាងក្រៅផ្លូវការដែលថា ពលកម្មកុមារ គឺជាមូលហេតុមួយនៃការថែទាំដោយឪពុកម្ដាយធម៌។ សំណួរគឺថា តើចំណុចនេះ គឺជាកត្តាជំរុញការថែទាំដោយឪពុកម្ដាយធម៌នៅប្រទេសកម្ពុជា មែនឬទេ ហើយសំខាន់ជាងនេះគឺថា តើកត្តាជំរុញមួយនេះបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះដល់កុមារមានពិការភាព។ តម្រូវការកម្លាំងពលកម្ម អាចជាកត្តារារាំងផង និងជាកត្តាជំរុញផង នៃការថែទាំកុមារមានពិការភាពដោយឪពុកម្ដាយធម៌៖ ជាកត្តារារាំងប្រសិនបើឪពុកម្ដាយធម៌ ចង់បានកូនដែលមាន"សុខភាពល្អ" ឬជាកត្តាជំរុញប្រសិនបើឪពុកម្ដាយធម៌ជឿថាពួកគាត់ ត្រូវបានអនុញ្ញាតឱ្យកេងប្រវ័ញ្ចកុមារមានពិការភាព ជាការតបស្នងចំពោះការថែទាំបន្ថែមដែលកុមារត្រូវការ។

## ការលើកទឹកចិត្ត និងការគាំទ្រដល់ឪពុកម្ដាយធម៌របស់កុមារមានពិការភាព

របាយការណ៍បច្ចុប្បន្ន ធ្វើសេចក្ដីសន្និដ្ឋានដោយផ្អែកលើអត្ថបទស្រាវជ្រាវ ក៏ដូចជាអ្នកជំនាញក្នុងការថែទាំដោយឪពុកម្ដាយធម៌។ វាគួរឱ្យចាប់អារម្មណ៍ផងដែរដោយត្រូវសិក្សាអំពីការជំរុញទឹកចិត្តដែលបានលើកឡើងដោយឪពុកម្ដាយធម៌ខ្លួនឯង។ តើពួកគាត់មើលឃើញកត្តារារាំងអ្វីខ្លះដល់ការថែទាំកុមារមានពិការភាព ហើយអ្វីខ្លះដែលបានជួយគាំទ្រដល់គាត់ក្នុងដំណើរការនេះ? វិធីសាស្ត្រខុសប្លែកប្រកបដោយភាពវិជ្ជមាន - ការសិក្សាលើគ្រួសារដែលបានថែទាំកុមារមានពិការភាពយ៉ាងជោគជ័យ - ត្រូវបានណែនាំជាជំហានបន្ទាប់ ដើម្បីស្វែងយល់ថា តើការគាំទ្រអ្វីខ្លះដែលឪពុកម្ដាយធម៌ត្រូវការ និងចង់បាន។



# អ្នកផ្តល់ព័ត៌មានសំខាន់។

| | |
|---|---|
| ថូ ម៉ានិត | Friends International |
| Lisa Yunker | Children in Families |
| Jess Whitney | Safe Haven |
| ស៊ាង ចំណាប់ | អតីតអង្គការ Hagar |
| អ៊ុង ប៉ូឡា | Holt International |
| ខេង សុខាវត្តី | Cambodian Children’s Trust |
| ស៊ាម សារាង | Grace House |
| ផ្លុង ឆាយ៉ា<br>កេង ម៉េងឡាង | UNICEF |
| ឈិន សារ៉ា | អង្គការម្លប់ឫស្សី |
| | សមាជិកនាយកដ្ឋានសុខុមាលភាពកុមារ និងនាយកដ្ឋានសុខុមាលភាពជនពិការ |



# ឯកសារយោង


EveryChild. (2011). *Fostering Better Care: improving foster care provision around the world*. Retrieved from

Hamilton, C., Apland, K., Dunaiski, M., & Yarrow, E. (2017). *Study on alternative care community practices for children in Cambodia*. Retrieved from

Jenny, M., Martin, D., & Burn, S. (n.d.). *Enhancing Alternative Care Opportunities for Children with Disabilities in Cambodia*. Retrieved from

Kheng, V. (20th November 2020). *កំណត់ហេតុកិច្ចប្រជុំជាមួយសមាជិកនាយកដ្ឋានសុខុមាលភាពកុមារ, ការិយាល័យគាំពារកុមារ, និងនាយកដ្ឋានសុខុមាលភាពជនមានពិការភាព។*

Kingdom of Cambodia. (2006). *គោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ។*

Light for the World Cambodia. (forthcoming). *Assessment of disability inclusion training 2018*. Retrieved from

Ministry of Social Affairs, V. a. Y. R. (2016). *ការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានី-ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា* Retrieved from

Palmer, M., Williams, J., & McPake, B. (2016). Standard of Living and Disability in a Low Income Country.

អ្នកចូលរួមទី១ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី២ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៣ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៤ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៥ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៦ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៧ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៨ (២០២០)/*អ្នកសម្ភាស៖ J. Baart*

អ្នកចូលរួមទី៩ (២០២០)/*អ្នកសម្ភាស៖ J. Baart*

Rethea, P. (25 September 2012). Social Work to change Cambodia. Retrieved from https://www.phnompenhpost.com/lifestyle/social-work-change-cambodia

Roby, J. L. (2020). *Supervision for staff of FCF | REACT partner organizations*. Retrieved from

Royal University of Phnom Penh. (2016). Background / Department of Social Work. Retrieved from http://www.rupp.edu.kh/fssh/social_work/?page=Background

Save the Children, & Center for Educational Research and Consulting. (2013). *Development Perspectives of Foster Care in Armenia: Research Analysis Results*. Retrieved from

UNICEF. (2011). *With the Best Intentions: a study of attitudes towards residential care*. Retrieved from

United Cerebral Palsy, & Children's Rights. (2006). *Forgotten Children: A Case for Action for Children and Youth with Disabilities in Foster Care*. Retrieved from

Webbink, E., Smits, J., & Jong, E. d. (2010). *Hidden Child Labour: determinants of housework and family business work of children in 16 developing countries*. Retrieved from

**អ្នកស្រាវជ្រាវ** ៖ Judith Baart

**រូបថតដោយ** ៖ Light for the World Cambodia, Disability Development Services Program, Save the Children Cambodia

Light for the World Cambodia
David Curtis
ទីប្រឹក្សាផ្នែកបរិយាបន្ន / អ្នកសម្របសម្រួលប្រចាំប្រទេស

d.curtis@light-for-the-world.org
Millennium Tower (1st floor)
#68 Street 57
Sangkat Boeung Keng Kang 1
Khan Chamkamorn, Phnom Penh



FAMILY CARE FIRST | REACT

## Ministries & Government Institutions

## REACT Partners Network

Together, building stronger child protection systems

## Members

## Donors